# ខេមរវេយ្យាករណ៍

## សម្រាប់ថ្នាក់
## មជ្ឈិមដ្ឋាន ឧត្តមដ្ឋាន និងទី ៦ ធំដើម

ការផ្សាយរបស់

លេខ ៨៨ វិថីអែមេគ្រង់ ភ្នំពេញ

នៅជិតរោងកុនព្រហ្មបាយន្ត ពីខាងកើតផ្ទាល់

ព. ស. ២៤៩៨ គ. ស. ១៩៥៥

ភ.59

R. ៤ 8-7-55
415.

# ខេមរវេយ្យាករណ៍

*Khemora Veyyākarana -*

សម្រាប់ថ្នាក់

មធ្យមដ្ឋាន ឧត្តមដ្ឋានទី៥ទី ៦ ទំនើប

លោកក៉ាយ - ប៊ុក

ក្រសួងឃោសនាការជាតិ

រៀបរៀង

បោះពុម្ពលើកទី ១

បណ្ណាគារ គីម - គី

រក្សសិទ្ធិ

ARCHIVES NATIONALES
DÉPÔT LÉGAL

បោះពុម្ពបញ្ចប់នៅថ្ងៃទី ១៨ មិថុនា ២៤៩៨ / ១៩៥៥

# មាតិការឿង


១ – អារម្ភកថា . . . . . . . . ទំព័រ . . .

២ – ប្រវត្តិនៃវេយ្យាករណ៍សាស្ត្រ „ ១

៣ – សញ្ញាណបឋម . . . . . . „ ១៣

៤ – អក្ខរៈ ឬ អក្សរ . . . . . . „ ២១

៥ – វណ្ណយុត្តិ . . . . . . . . . „ ៣៣

៦ – នាមសព្ទ . . . . . . . . . „ ៥៥

៧ – គុណនាម . . . . . . . . „ ៧០

៨ – សព្វនាម . . . . . . . . „ ៩៤

៩ – កិរិយាសព្ទ . . . . . . . . „ ១០៦

១០ – កិរិយាវិសេសន៍ . . . . . . „ ១១១

១១ – អាយតនិបាតសព្ទ . . . . „ ១១៦

១២ – សន្ធានសព្ទ . . . . . . „ ១១៩

១៣ – ឧទានសព្ទ . . . . . . . . . „ ១២២

# អារម្ភកថា

វេយ្យាករណ៍ខ្មែរ, ខ្ញុំបានរៀបរៀងដើម្បីទុកឲ្យកូនចៅខាងក្រោយរៀនសូត្រ ព្រមទាំងពង្រីកអក្សរសាស្ត្រខ្មែរឲ្យមានពលភាព មានរបៀបរៀបរយទៅតាមសម័យនិយម ។ អក្សរសាស្ត្រខ្មែរដែលមានវឌ្ឍនធម៌ទៅអនាគត មកពីមានវេយ្យាករណ៍ខ្មែរត្រឹមត្រូវ ជាហេតុឲ្យសរសេរសព្ទ ឬពាក្យទៅតាមអក្ខរាវិរុទ្ធ ឬទៅតាមវិធាននៃវេយ្យាករណ៍ ។ កិច្ចការទាំងនេះនាំឲ្យស្រួលដល់អ្នកសិក្សារៀនសូត្រ ងាយចំណាំពាក្យ ងាយនឹងទន្ទេញចាំ, ស្រួលនឹងកំណត់ក្នុងចិត្ត មិនដូចបុរាណដែលសរសេរអ្វីតាមចិត្តដូចជាប៉ាក់ពូក, ប៉ាក់អាវ, មិនងាយនឹងចំណាំបានដែលសព្វថ្ងៃគេសរសេរដូចនេះ : បក្សពូក, ប៉ាក់អាវ ។

បើតាមពិនិត្យវេយ្យាករណ៍ខ្មែរ នឹងវេយ្យាករណ៍បារាំងឃើញវេយ្យាករណ៍យើងមិនទាន់បានចម្រើននៅឡើយ ព្រោះភាសាបារាំងថា: *Un homme beau, une femme belle, tous les hommes sont beaux, toutes les femmes sont belles, les femmes et les hommes sont beaux.* ។ បើភាសាខ្មែរថា: បុរស

ស្អាត' ស្រីស្អាត, បុរសទាំងអស់ស្អាត, ស្រីទាំងអស់ស្អាត' បុរសនឹងស្រីទាំងអស់ស្អាត ។ បើទុកជាយ៉ាងណាពាក្យ ស្អាតនេះគ្មានប្រែប្រួលមិនមានសំគាល់ថា បុំលិង្គ' ឥត្ថីលិង្គ, នបុំសកលិង្គ, ឬឯកវចនៈ ពហុវចនៈ ។ អំពីការពិនិត្យឲ្យជ្រៅជ្រះ (Syntaxe) ក៏ពុំទាន់មានបរិបូណ៌ ។ ដូចនេះ តើបណ្ឌិតវេយ្យាករណសាស្ត្រសម័យបច្ចុប្បន្ន អាចរចនាភាសាខ្មែរឲ្យមានរបៀបទៅបានឬ? ដូចជាថា បុរសស្អាត, ស្រីស្អាតី, បុរសទាំងអស់ស្អាតិ, ស្រីទាំងអស់ស្អាតំ បុរសនឹងស្រីទាំងអស់ស្អាតំជាដើម ។ នេះគ្រាន់តែជាឧទាហរណ៍សម្រាប់ជូនបណ្ឌិតវេយ្យាករណ៍ដែលចំណានសម័យបច្ចុប្បន្ន ឲ្យពិចារណាហើយលៃលកដាក់ពាក្យខ្មែរឲ្យមានរបៀបស្រួលនឹងចំណាំ ដើម្បីវិវត្តន៍ភាសា នឹងអក្សរខ្មែរទៅតាមសម័យនិយម ។

អវសាន ខ្ញុំសូមឧទ្ទិសកុសលដែលកើតពីសេចក្ដីព្យាយាមរបស់ខ្ញុំ ជូនទៅបិតាមាតានឹងគ្រូអាចារ្យព្រមទាំងមាតុភូមិរបស់ខ្ញុំ សូមឲ្យស្ថិតនៅគង់សេចក្ដីសុខ-ចំរើនជាកេយ្យាគាពតទៅ ។

ភ្នំពេញ នៅថ្ងៃទី ៥ ឧសភា ១៩៥៥

ហ៊យ-ប៊ុក

# ១ – ប្រវត្តនៃវេយ្យាករណសាស្ត្រ

ការសិក្សាវេយ្យាករណសាស្ត្រ គឺ ធ្វើតាំងពីបុរាណកាល ខាងបូព៌ាទ្វីប ឬ ខាងបស្ចិមទ្វីប ។ ការស្រាវជ្រាវនៃបណ្ឌិតវេយ្យាករណសាស្ត្រ ហិណ្ឌូ ដែលមានបណ្ឌិត បាណិនិ ជាប្រធាន (ក្នុងសតវត្សទី ៤ មុន គ.ស.) មានកិត្តិសព្ទល្បីល្បាញអស្ចារ្យពន់ពេក ។ វេយ្យាករណ៍សាស្ត្រខាងបស្ចិមទ្វីប គឺ ជាតិក្រិកជាអ្នកបង្កើត ។ ពួកអ្នក ចារណញ្ញាណបទុំ (Sophistes), លោកទស្សនវិទូក្រេកប្លាតុង នៅក្នុងសៀវភៅនាមថា: "Cratyle" បានលើកដំកើងជាកិត្តិយសចំពោះការអបរំខាងវេយ្យាករណសាស្ត្រ ។ ពួកនេះបានព្យាយាមរកនូវបុព្វហេតុនៃពាក្យឬសព្ទ ។ លោកទស្សនវិទូក្រិក, អារិស្តូត បានបញ្ជាក់ថា: "ជោគវាសនានៃវេយ្យាករណ៍សាស្ត្រមានហេតុបច្ច័យទាក់ទងនឹងបច្ច័យវិទ្យា (Logique)" ។ ពួកខន្តី (Stoiciens) បានរៀបចំ, បែងចែកវេយ្យាករណ៍សាស្ត្រជាបួនករណី គឺ: នាម (nominatif) បច្ច័យ (génitif), កាល: (datif) កម្ម: (accusatif) ។ ពួកបណ្ឌិតវេយ្យាករណសាស្ត្រនៅទីក្រុងអាលេកសងឌ្រី

សុទ្ធតែពួកអក្សរសាស្ត្របណ្ឌិត  មានបំណងចង់រចនាកាព្យឲ្យមានបណ្ឌិត "ហូមែរ" ឲ្យបានបរិសុទ្ធស្អាត ៗ ពួកនេះបានខំកំណត់នូវវិធានការខ្លះនៃវេយ្យាករណ៍ ៗ មានពួកបណ្ឌិតវេយ្យាករណ៍នៅទីក្រុងប៉ែរកាម (ប្រទេសអាស៊ី មីណើរ) ជាបច្ចាមិត្រពួកអលេកសង់ដ្រាំង,  បានទទួលពីបណ្ឌិតនេះនូវបញ្ជីពាក្យដែលគេមិនប្រើ ៗ ពួកបណ្ឌិតនេះយល់ថា: ត្រូវទុកពាក្យដែលមានន័យផ្ទុយអហេតុកវិជ្ជា (anomalie) សភាពខុសពីធម្មតា ជាបទបញ្ញត្តិច្បាប់ភាសា; អ្នកដែលយល់ផ្ទុយពីនេះគឺជាពួកហេតុកវិជ្ជា (analogie)។ លោកដឺនិស ដ៏ស្ត្រាស់បាននិពន្ធ, ក្នុងសតវត្សរ៍ទី ១ មុន គ. ស., នូវសៀវភៅមួយឈ្មោះ «តម្រាវេយ្យាករណ៍" ដែលមានអានុភាពផ្សាយអស្ចារ្យ, ហើយវេយ្យាករណ៍នេះគេទុកជាក្បួនស្វ័យពជ ក្នុងពេលនោះ ៗ ក្នុងសតវត្សរ៍ទីពីរនៃ គ. ស., លោក អប៉ូលូនីយសឌិស្កូលបាននិពន្ធដោយជាក់លាក់នូវតម្រារូបសាស្ត្រ(morphologie ពួករ៉ូម៉ាំងបានខំព្យាយាមសិក្សា វេយ្យាករណ៍ជាយ៉ាងស្វាហាប់ តែមិនសូវបានផល;  ពួកនេះបានប្រែនូវអវសានសព្ទភាសាក្រិកជា

ភាសាឡាតាំង ៗ នៅមធ្យមយុគ, គ្មានការចំរើនខាងកិច្ចសិក្សា វេយ្យាករណ៍ទេ ៗ នៅសតវត្សរ៍ទី១៦នឹងជាដំបូងនៃសតវត្សរ៍ទី១៧, ពួកបណ្ឌិតខាងវេយ្យាករណ៍បារាំង គឺ មានតែពួកបេះភាសាសាស្ត្រ សុទ្ធ ៗ មិនដឹងនូវប្រវត្តិភាសាសាស្ត្រ ហើយច្រើនប្រកាន់នូវទស្សនវិជ្ជាហួសហេតុ ៗ ការរៀបចំបែងចែកពាក្យ ខាងភាសាបារាំងនេះ កើតឡើងដោយភាគច្រើនចំពោះការព្យាយាមនៃពួកបណ្ឌិតនេះបាន ជាមានពាក្យផ្ទុយ, ពាក្យសុខុម ៗ តាំងពីកើតសៀវភៅវេយ្យាករ-ណ៍ ប៉ូរ៉ូយ៉ាល់ (១៦៦០) មានគេនិពន្ធសៀវភៅវេយ្យាករណ៍ជាច្រើន; អ្នកនិពន្ធ បានខំស្វះស្វែងរកគោលការជាសមុហភាពរវាងគ្រប់ភាសាទាំងអស់ ៗ ចំពោះអ្នកនិពន្ធ, វេយ្យាករណ៍, មាន លោកបូហ្វេ ១, លោកកុងឌីយ៉ាក់ ១, លោក ឌុយ ម៉ារសេស ១, លោកដេស្ទុតដឺត្រាស៊ី ១, ៗ ចុងសតវត្សទី ១៨, មានព្រឹត្តិការណ៍សំខាន់ក្នុងប្រវត្តិនៃវេយ្យាករណ៍ គឺ. ការរកឃើញភាសាសំ-ស្រ្កឹត ៗ បន្តិចទៀត "វេយ្យាករណ៍ទូទៅ" នឹងបាត់ហើយនឹងលេចចេញនូវ " វេយ្យាករណ៍តាមប្រវត្តិសាស្ត្រនឹងប្រៀបធៀប " វិញ

របៀបនៃការពិសោធន៍ ត្រូវរបៀបសំដែងហេតុផលមានអានុភាពជា លំដាប់តទៅមានភាសាសាស្ត្របណ្ឌិត ៣ នាក់យ៉ាងបំណានជាងគេ ត្រង់ប្រើតម្រាសំដែងហេតុផលគឺៈ លោកប៉ុប្ប, គ. ស. ១៨៣៣ ក្នុងសៀវភៅ "វេយ្យាករណ៍ប្រៀបធៀបចំពោះភាសាឥណ្ឌូ-សែរម៉ានិក", លោកសាកុប-គ្រិម្ម, គ. ស. ១៨១៩, ក្នុងសៀវភៅ "វេយ្យាករណ៍អល្លឺម៉ង់", លោកហ្វ្រេដេរិកឌីយេ, គ. ស. ១៨៣៦, ក្នុងសៀវភៅ "វេយ្យាករណ៍ប្រៀបធៀបភាសារ៉ូម៉ាន" តែការស្វែងរកបែបនេះ ចូលទៅក្នុងវិជ្ជាមួយដែលហៅថាភាសាសាស្ត្រ ។

ចំណែកឯប្រវត្តិនៃវេយ្យាករណ៍ខ្មែរ ខ្ញុំលំបាកនឹងស្រាវជ្រាវពន់ពេក ព្រោះវេយ្យាករណ៍ខ្មែរមានបច្ច័យទាក់ទងនឹងវេយ្យា-ករណ៍សំស្ក្រឹតនឹងបាលី ។ ឯវេយ្យាករណ៍សំស្ក្រឹតនឹងបាលី ប្រហែលជាមានបណ្ឌិតបាននិពន្ធតាំងពីសម័យអង្គរធំ, បានជាមានសិលាចារឹកជាភាសាសំស្ក្រឹត តែខ្ញុំសូមពោលត្រឹមតែសម័យបច្ចុប្បន្ន, មានសៀវភៅកច្ចាយនរូបត្ថកៈ របស់សម្ដេចព្រះមហា

សុមេធាធិបតី ជួន-ណាត នាមឆាយា ជោតញ្ញាណោ សង្ឃនាយក គណៈមហានិកាយ; លំដាប់តមកមានវេយ្យាករណ៍សំស្ក្រឹត របស់ព្រះពោធិវង្ស ហួត-តាត, នាមឆាយា វិជិរបញ្ញោ ចាងហ្វាងសាលាបាលីជាន់ខ្ពស់ (៩ កញ្ញា ១៩៤០) រួចសៀវភៅវេយ្យាករណ៍ប្វាប របស់លោកអាចារ្យ អ៊ុក-ជា, វេយ្យាករណ៍ខ្មែរថ្នាក់បឋមដ្ឋាន និងទុតិយដ្ឋាន របស់លោកគ្រូ ពូរ-អ៊ុម (១៩៥០), វេយ្យាករណ៍និងភាសាខ្មែរសម្រាប់ថ្នាក់ បវិឋនដ្ឋាន - អាទិកដ្ឋាន (១៩៥៣) ។

## ប្រវត្តិវេយ្យាករណ៍ (ជាគាព្យ)

(ពាក្យ៧)

ការសិក្សាវេយ្យា- ករណ៍បុរាណ
មានតាមលំអាន បុព្វាទិ៍ប
បណ្ឌិតហិណ្ឌ ជាប្រទីប
ខាងបស្ចិមទ្វីប កបសព្វគ្រប់ ។
ហិណ្ឌុបាទិ- និប្រធាន

មាននាមកល្យាណ ល្បីទិសដប់
កុងសតវត្សប្អូន តែងប្រាជ្ញ
មានកិត្តិសព្ទ មុនយីស៊ូ ៗ
ជាតិក្រិករូមាំង ខំព្យាយាម
បណ្ឌិតបុះនាម ប្លាតុងគ្រូ
អារីស្តូតប្រាជ្ញ ខំតស៊ូ
រកពាក្យគំរូ អប់រំរក ៗ
ពួកខន្តីបាន រៀបចំចែង
ព្យាយាមប្រឹងប្រែង បែះភាពយក
វេយ្យាករណ៍ជូន ខំលៃលក
នាមបច្ច័យមក កាលកម្ម ១
ភាឡ៊ែកសង់ថ្មី មានបណ្ឌិត
ខិតខំគួរគិត តាមប្រាជ្ញា
កាព្យទិដ្ឋានហូ- មែរថ្ងៃថ្លា
តែអគ្គរូបា៉ ឲ្យបានស្អាត ៗ

បញ្ចើរពាយពាក្យ　　គេមិនប្រើ
បណ្ឌិតប្រសើរ　　ប៉ែរតាមខ្នាត
បានដកស្រង់ចុះ　　តាមឌុក់ទ
ពួកនេះធ្វើខ្វាត　　ខុសធម្មតា
ដីទិស្តដីស្ត្រាស　　ប្រាជ្ញវេយ្យាករណ៍
ស្វែងរកខ្មោស　　ក្បួនត្រា ។
អប៉ុល្លីយស　　ឱស្កលណា
ខិតខំរចនា　　ទូវរូបសាស្ត្រ ។
ពួកជាតិរ៉ូមាំង　　បានព្យាយាម
ប្រែក្រិកជានាម　　ឡាតាំងសាសន៍
មជ្ឈមយុគ្គកាល　　គ្មានស្រឡះ
បណ្ឌិតរៀនច្បាស់　　វេយ្យាករណ៍ ។
សតវត្សដប់-　　ប្រាំមួយកប
ដប់ប្រាំពីរស្រប　　ប្រាជ្ញបវរ
បង្កើតពាក្យផ្ទុយ　　សុខុមល្អ

ផាប្រែនខណ្ឌ　　ក្នុងពេលនោះ ។
តាំងពីកើតឡើង　　វេយ្យាករណ៍
ប៊ូរក៊ុំយ៉ាល់ចរ　　ល្បីមានឈ្មោះ
គោលការសម្បូ-　　ហភាពស្មោះ
គ្រប់ភាសាឆ្ពោះ　　វឌ្ឍនា ។
វេយ្យាករណ៍ប្រ-　　វត្តិសាស្ត្រ
បានថ្លែងប្រកាស　　តាមភាសា
សំស្ក្រឹត ភាល្ចឹមឯង　　រូម៉ានណោ
ចូលក្នុងត្រា　　ភាសាសាស្ត្រ ។
ប្រវត្តិវេយ្យា-　　ករណ៍ខេមរា
មានបុរាណ　　ភ្ជឹទិកាស
សម័យអង្គរ　　ប្រាជ្ញពេញពាស
សុខ្ខូតដុម្ពឹងមាស　　ខាងវេយ្យាករណ៍ ។
សិលាចារិក　　បានទុកកេរ្តិ៍
មិនមានទំនេរ　　ចារអក្សរ

| | |
|---|---|
| ទុកឲ្យជនខ្មែរ | ទំត្រេចបវរ |
| ស្វាធ្យាយខ្មោស | តាមត្រូវការ ៗ |
| ភាសាសំស្ក្រឹត | នឹងបាលី |
| ខ្មែររកសួស្ដី | ប្រវត្តិបារ |
| តាមព្រៃកំថ្ម | ដ៏អស្ចារ្យ |
| នៅកន្ទុគុហារ | ប្រាង្គប្រាសាទ ៗ |
| បណ្ឌិតវេយ្យាករណ៍ | ខ្មែរគំរូ |
| កក្លាយ ឧប- | តម្ងក:ស្អាត |
| សម្ដេចសង្ឃ- | នាយកណាត |
| រចនាតាមខ្នាត | គាប់ប្រសើរ ៗ |
| ក្បួនវេយ្យាករណ៍ | សំស្ក្រឹតជាក់ |
| ឧត្ដមសមសក្ដិ | កបដំណើរ |
| ព្រះពោធិវង្ស | ហួតតាកធ្វើ |
| គួរឲ្យសរសើរ | ប្រាជ្ញញាណ ៗ |
| អាចារ្យអ៊ុកជា | អ្នកវិជ្ជូរ |

រចនាគិតគូរ　　តាមលំអាន
វេយ្យាករណ៍ម្ចាប់　　ជាប្រធាន
គួរឲ្យសន្និដ្ឋាន　　តម្រាឯក ៗ
លោកគ្រូ ពូរ-អ៊ុម　　បាននិពន្ធ
វេយ្យាករណ៍ខ្មែរគ្រាន់　　លោកបែងចែក
សព្វនាមកិរិយា　　សម្ពន្ធញែក
ស្រាវជ្រាវគល់មែក　　វេយ្យាករណ៍ ៗ
មានវេយ្យាករណ៍　　ភាសាខ្មែរ
បណ្ឌិតចំប្រែ　　គួរត្រេកអរ
តែមិនស្គាល់ឈ្មោះ　　សែបវ៉ែរ
សៀវភៅនេះល្អ　　ដ៏ចំឡែក ៗ

## ពាក្យសួរ

ការសិក្សាវេយ្យាករណ៍កើតឡើងពីកាលណា? នៅទ្វីបណា?

បណ្ឌិតវេយ្យាករណ៍ហិណ្ឌូនាមអ្វី? ក្នុងសតវត្សទីប៉ុន្មាន?

វេយ្យាករណ៍បស្ចិមទ្វីប ជាតិណា ជាអ្នកស្ថាបនា មុនដំបូង? លំដាប់តមក, តើមានជាតិណា ជាអ្នកតិតរៀងវេយ្យាករណ៍តៗទៅទៀត? មានបណ្ឌិតនាមឈ្មោះអ្វីខ្លះ? ពួកបណ្ឌិតនៅទីក្រុងអាឡិចសង់ឌ្រី បានធ្វើអ្វីខ្លះចំពោះវេយ្យាករណ៍នេះ? ចំណែកពួកបណ្ឌិតខាងវេយ្យាករណ៍នៅទីក្រុងប៉ែរកាម (ប្រ. ទសអាស៊ីមីណឺរ) តើលោកបានធ្វើអ្វីខ្លះ?

តម្រាវេយ្យាករណ៍ របស់លោកដឺនិសដឺត្រាស បាននិពន្ធពីសតវត្សទីប៉ុន្មាន? លោកអប៉ូលូនិយស - ឌីស្កូលបាននិពន្ធសៀវភៅអ្វីខ្លះ?

តើពួករ៉ូម៉ាំងបានប្រែសៀវភៅអ្វីខ្លះ?

នៅមជ្ឈមយុគមានការបម្រើនខាងវេយ្យាករណ៍ឬទេ?

នៅសតវត្សទី ១៦ និងគ្រាដម្បូងនៃចុងសតវត្សទី ១៧ មានពួកបណ្ឌិតខាងវេយ្យាករណ៍ បារាំងបានធ្វើអ្វីខ្លះ?

តើសៀវភៅវេយ្យាករណ៍ ប៉ូរ៉ូយ៉ាល់ បាននិពន្ធ តាំងពីកាលណាមក? ក្នុងពេលនោះ តើមានពួកបណ្ឌិតខាងវេយ្យាករណ៍ប៉ុន្មាន

នាក់? នាមឈ្មោះអ្វីខ្លះ?

នៅចុងសតវត្សទី ១៨ មានព្រឹត្តិការណ៍សំខាន់ក្នុងប្រវត្តិវេយ្យាករណ៍យ៉ាងណាខ្លះ?

មានភាសាសាស្ត្របណ្ឌិតប៉ុន្មាននាក់, គេនាមឈ្មោះអ្វីខ្លះ, បានធ្វើសៀវភៅអ្វីខ្លះ? គ. ស. ប៉ុន្មាន?

វេយ្យាករណ៍ខ្មែរមានបច្ច័យទាក់ទងនឹងវេយ្យាករណ៍ភាសាណា? សៀវភៅកច្ចាយនូបត្ថម្ភក: តើបណ្ឌិតណា បាននិពន្ធ? បណ្ឌិតខាងវេយ្យាករណ៍ខ្មែរមានប៉ុន្មាននាក់? បាននិពន្ធសៀវភៅអ្វីខ្លះ?

## ២ - សញ្ញាណបឋម

មុននឹងពណ៌នាអំពីវេយ្យាករណ៍ ខ្ញុំសូមពោលអំពីបុព្វហេតុដែលនាំឲ្យកើតវេយ្យាករណ៍ ។

ធម្មតាវត្ថុក្នុងលោកដែលកើតឡើងហើយត្រូវមានបទបញ្ញត្តិ, ច្បាប់, វិធាន, របៀបបែបផែនដូចជាភាសា, អក្សរជាតិ, មនុស្ស, សត្វ, អសង្ហារិម, សសង្ហារិម, ប្រទេស, ជាតិជាដើម ។ ភាសាអក្សរជាតិត្រូវមានបទបញ្ញត្តិ, ច្បាប់, វិធាន ដើម្បីនឹងធ្វើភាសា, អក្សរជាតិនោះឲ្យមានរបៀបរៀបរយ ត្រឹមត្រូវតាមក្បួនខ្នាត; ដោយនឹងសំគាល់ បំណាំ; ដោយនឹងសិក្សារៀនសូត្រជាហេតុធ្វើភាសានឹងអក្សរជាតិនោះឲ្យមានតម្លៃក្នុងលោក ។ ភាសានឹងអក្សរជាតិណាគ្មានរបៀបគឺ គ្មានអក្ខរាវិរុទ្ធ, ចង់ដាក់យ៉ាងម្តេចក៏ដាក់ទៅ, តាមអំពើចិត្តគេហៅថាភាសាអក្សរជាតិថោកទាប, ហិនភាព ។ ព្រោះហេតុដូច្នេះបានជា បណ្ឌិតទាំងឡាយលោកមានបំណងចង់ឲ្យអ្នកពោលនឹងអ្នកសរសេរ, ពោលភាសាទៅតាមវិធានពិសេស, សរសេរអក្សរទៅតាមអក្ខរាវិរុទ្ធ បើនា

ភាសា, អក្សរៈនោះទៅតាមសម័យនិយម, កែប្រែភាសា, អក្សរទៅតាមវិវត្តន៍របស់លោក, ឲ្យចូលក្នុងចំណោមនឹងគេបាន, កុំឲ្យនៅក្រៅសង្វៀន, រើសតែពីក្រៅ, តើបានអ្វីនឹងចេញមុខទៅសន្ទនាការ នឹងមហាប្រទេសបាន? ។ ព្រោះហេតុដូច្នេះជាតិទាំងអស់ក្នុងលោកគេព្យាយាមរចនាភាសានឹងអក្សរជាតិ របស់គេ ឲ្យទៅជាភាសាឬអក្សរការទូតដែលគេយកទៅប្រើក្នុង មហាសន្និបាតដូចជាអង្គការសហប្រជាជាតិ, គណៈកម្មការរវាងជាតិ, សន្និសីទជាដើម ដូចជាភាសាអង់គ្លេសនឹងបារាំង ។

អាស្រ័យហេតុខាងលើនេះ, បានជាបណ្ឌិតខាងអក្សរសាស្ត្រលោកបានស្ថាបនានូវវិជ្ជាមួយ ហៅវេយ្យាករណ៍ ឬវៃយាករណ៍ ។

វេយ្យាករណ៍ជាពាក្យកើតមកពីភាសាមគធ: វៃយាករណ៍ជាពាក្យកើតមកពីភាសាសំស្រ្កឹត ប្រែថាធ្វើឲ្យជាក់ច្បាស់, ឲ្យប្រាកដ; ការពន្យល់; ពាក្យអធិប្បាយ; ពាក្យដោះស្រាយ, ពាក្យពាយ, ចំនាយ ។ វេយ្យាករណ៍ ឬវៃយាករណ៍ ជាគម្ពីរច្បាប់គោលរបស់ភាសា, មូលរបស់ភាសា ។

ធម្មតាភាសាត្រូវមានវិធានការពិសេស ដែលអប់រំឲ្យពោលពាក្យត្រឹមត្រូវ, សរសេរទៅតាមអក្ខរាវិរុទ្ធរបស់ពាក្យ ។ វិធានការទាំងអស់នេះគេហៅថា វេយ្យាករណ៍ ។

វេយ្យាករណ៍ ជាវិជ្ជាមួយដែលបង្ហាត់បង្រៀនយើងឲ្យពោលពាក្យ ឬសរសេរពាក្យកុំឲ្យខុស ។

## ពាក្យ អក្ខរៈ

ដើម្បីនឹងពោល ឬសរសេរគេប្រើពាក្យ ។

ពាក្យនេះបញ្ចេញសភាពឲ្យឃើញនូវគំនិតរបស់យើង ។

ពាក្យមានពីរយ៉ាងគឺ:

ពាក្យនិយាយឬពោល នឹងពាក្យដែលសរសេរ ។

ពាក្យនិយាយមានសំឡេងនឹងសូរ ។

ពាក្យសរសេរមានអក្ខរឬអក្សរ ។

អក្សរគឺ ជាគំនូសរបស់សំឡេងដែលពោល ឬគំនូសសូរសំឡេងដែលបញ្ចេញ ។

# វាចាឬសំដី - ភាសា

វាចាឬសំដីគឺជា មធ្យោបាយដើម្បីបញ្ចេញនូវគំនិត ។

គេអាចដឹងគំនិតបានដោយមធ្យោបាយបីយ៉ាងគឺៈ

១- ដោយគំនូសគឺៈ វាចាសកម្មភាព

២- ដោយសំដីគឺៈ វាចាដែលពោល

៣- ដោយអក្សរគឺ វាចាសរសេរ

ភាសាជាវិធានពិសេសដែលប្រើជាជនបញ្ចេញនូវគំនិតសព្វ ៗ ខ្លួនដោយវាចាឬដោយអក្សរ ។ ភាសាមានពីរយ៉ាងគឺៈ

១- មរណភាសាឬភាសាស្លាប់ ជាភាសាដែលគេលែងនិយាយ ដូចជាភាសាឡាតាំង, ភាសាក្រេកបូរាណ, ភាសាបាលី, ភាសាសំស្រ្កឹតជាដើម ។

២- ជីវភាសាឬភាសារស់ ជាភាសាដែលគេពោលសម័យបច្ចុប្បន្ន ដូចជាភាសាខ្មែរ, អង់គ្លេស, បារាំង, អល្លឺម៉ង់, ចិន, យួន, ជប៉ុន ជាដើម ។

# គំនិត

គំនិតគឺ ការបញ្ចេញរូបនិមិត្តក្នុងមនោភាពបទ: ឬការបញ្ចេញនូវអារម្មណ៍ក្នុងមនោទ្វារ ឬថាចិត្តដែលគិត, ពិនិត្យ, ស្ទង់គំនិត ៗ ដូចយើងពោលថាស្រី, យើងឃើញអារម្មណ៍ទ្រង់ទ្រាយថារូបមានសក់អ៊ុត. មុខប្រស់ម្សៅ, បបូរមាត់លាបក្រហម, ពាក់អាវ, ស្លៀកសម្ពុយ.....

បើគំនិតនោះចេញទៅ ខាងមាត់ទើបពោលពាក្យសំដីទៅតាមគំនិតនោះ. បើគំនិតនេះចេញទៅខាងអវយវៈ ដៃ, ជើង, ទីប្រ-ព្រឹត្តអាការៈ ឬធ្វើការទៅតាមចិត្តដែលគិតនោះ ៗ

បុព្វហេតុដែលកើតវេយ្យាករណ៍មកពីអ្វី ?យ៉ាងដូចម្ដេចដែលហៅថាភាសា? អក្សរប៉ាកទាប? អ្វីដែលហៅថាភាសាឬអក្សរការទូត ?

ពាក្យថា វេយ្យាករណ៍ មានន័យថាដូចម្ដេច ?

អ្វីដែលហៅថាពាក្យ? ពាក្យមានប៉ុន្មានយ៉ាង ?

អ្វីដែលហៅថាអក្ខរៈ ឬអក្សរ?

អ្វីដែលហៅថាវាចា ឬសំដី? វាចាមានប៉ុន្មានយ៉ាង?

ភាសាជាអ្វី? មានប៉ុន្មានយ៉ាង?

គំនិតបានសេចក្ដីថាយ៉ាងណា?

## ពាក្យសួរ

### សញ្ញាណបឋម (កាព្យពាក្យ៩)

ធម្មតាសត្វ  រុក្ខជាតិ  នៅលើដី
កើតឡើងស្ដី  មានបទច្បាប់  សម្រាប់គ្រប់
មានវិធាន  បែបរបៀប  ផែនប្រារព្ធ
ធម្មជាតិសព្វ  មានបញ្ញត្តិ  តាមលំអាន ។
ភាសាសត្វ  អក្សរជាតិ  មានក្បួនច្បាប់
ប្រកបសព្វ  ពាក្យវេយ្យាករណ៍  មានរូបប្រាណ
ល្អស្អាតសម  ភាសារស  ល្បីទីស្ថាន
អង់គ្លេសបាន  បារាំងថៃ  ប្រែវណ្ណនា ។

ភាសាខ្មែរ    បើអ្នកប្រាជ្ញ    វិពិទិត្យ
គោលកែពិត    ងងឹតក្ដី    គួររចនា
ឲ្យបានទាន់    សម័យទៀត    កបលោកា
ខាត់រូប៉ា    គង់បានស្អាត    បម្រើនគ្រប់ ៗ
ជាតិដទៃ    គេព្យាយាម    ដុសខាត់ដៅ
មាន់ចិត្តក្ដៅ    រលាវក្ដែង    សង្វៀនកប់
ជនជាតិខ្មែរ    ខំប្រែកែ    អប់រំជប
គង់ប្រសប់    បានប្រសើរ    ភាសារស ៗ
ពាក្យនិយាយ    មានសំឡេង    សព្ទសូរសៀង
ទីងត្រង់ស្មៀង    ពាក្យសរសេរ    មានកិត្តិយស
តួអក្ខរៈ    គំនូសសព្ទ    សូរក់យគោះ
សំដីឈ្មោះ    ក៏ចាតាម    ភាសាសត្វ ៗ
សំដីចេញ    ដឹងគំនិត    ចិត្តបំណង
ពាក្យសាសង    ល្អលាមក    គ្រងចងចាត់
ផ្អែមជូរល្វីង    ប្រែសាបរស    សខ្មៅកាត់

ខំដុសខាត់ យូរឆ្នាំខែ ទាល់ភ្នែកខ្លួន ៗ
គូរគំនូស ហៅអក្សរ ប្អក្ខរៈ
ចេញចិត្តៈ ស្គាល់គំនិត ត្រិជាប់សឹង
ក្រៅសំណាញ់ ដូចបក្សា ជាប់ខ្សែដូង
ទឹកល្អក់រង បញ្ចេញភាព ឲ្យស្គាល់ជាក់ ៗ

## ៣- អក្ខរៈ ឬអក្សរ

អ្វីហៅថា អក្ខរៈ ឬអក្សរ ? អក្ខរៈ ឬអក្សរ បានន័យថាស្នាមគំនូសមានតួកងផ្សេងៗសម្រាប់ប្រើសរសេរកត់ពាក្យសំដីនិងសេចក្ដីគំនិតខ្លួន ប្រើមិនចេះអស់ ។

អក្ខរៈ មានពីរយ៉ាងគឺៈ ស្រៈ ១, ព្យញ្ជនៈ ១ៈ ។

### ស្រៈ

ស្រៈមកពីមគធភាសាថា សរៈ ឬភាសាសំស្ក្រឹតប្រែថា សូរ ។ ស្រៈបានន័យថាអក្សរដែលអាចបញ្ចេញសំឡេងខ្លួនឯងបានផង, អាចនាំព្យញ្ជនៈឲ្យចេញសំឡេងបាន មានសូរព្រុកងរពងរបស់ព្យញ្ជនៈផង ។ ស្រៈគឺសូរសំឡេងគឺអក្ខរៈដែលបញ្ចេញសូរសំឡេង ។

ស្រៈដែលផ្សំជាមួយនិងនិគ្គហិតព្រមទាំងវិសជ៌នីយផងមាន ២១ តួគឺៈ

អ អា អិ អី អឹ អឺ អុ អូ អួ អើ អឿ អៀ អេ
អែ អៃ អោ អៅ អុំ អំ អាំ អះ ។

*បើរាប់ទាំង ឫ ឬ ឭ ឮ ទីនខ្ទុំ ផងជា ២៦ តួ ។*

ស្រៈមានពីរយ៉ាងគឺៈ

១– ស្រៈពេញតួមាន ១៥ តួៈ

អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

ស្រៈនិស្ស័យមាន ២១ តួៈ

/ ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ

ៅ ុំ ំ ាំ ះ ។

ស្រៈពេញតួបែកចេញជាពីរយ៉ាងគឺៈ

១ – *រស្សៈ គឺស្រៈដែលពោលបានដោយសូរឆាប់រហ័សៈ*

អ ឥ ឧ ឩ ឫ ឭ ឰ ឱ ។

២ – *ទីឃៈ គឺស្រៈដែលពោលដោយបន្លឺសូរវែងៈ*

អា ឦ ឯ ឬ ឮ ឳ ។

# ស្រៈនិស្ស័យបែកចេញជាពីរយ៉ាងគឺៈ

១- រស្សៈ / ិ ឹ ុំ ុំ ាំ

២- ទីឃៈ ា ី ឺ ូ ួ ើ ឿ ៀ េ ែ

ៃ ោ ៅះ ។

## សេចក្ដីបញ្ជាក់អំពីស្រៈ

ស្រៈ អា ជាទីឃៈ ក្នុងពាក្យ "ខាត", បើមានរស្សៈសញ្ញាឬបន្តក់ខាងចុង, ជារស្សៈក្នុងពាក "អាត់" ។

ស្រៈ អ ជាទីឃៈ ក្នុងពាក្យ ' កត" បើមានរស្សៈសញ្ញាឬបន្តក់ខាងចុងជាពាក្យរស្សៈ ក្នុងពាក្យ "កត់" ។

ស្រៈ ិ បើមានទណ្ឌឃាតឬបដិសេធ មានសំឡេងជាទីឃៈ ក្នុងពាក្យ "ក្សត្រិយៈ", បើមានទណ្ឌឃាត, មានសំឡេងទៅជារស្សៈ ក្នុងពាក្យ "ក្សត្រ៍យ" ។

ស្រៈ "ះ" បើដាក់ពីមុខពាក្យជាភាសាបាលីទៅជាមានសូរសំឡេងជា "អ័ក" ដូចជាពាក្យថា ស្រៈ; បើដាក់ពីមុខពាក្យ

ជាភាសាខ្មែរ ដូចជាស្រះឈូក នៅជាមានសូរសំឡេងជា "អ័ស" នៅវិញ ។

ស្រៈ ំ ត្រូវគ្នានឹង ម ដូចជា ក្រំ ឬ ក្រម ។

ស្រៈ ុំ ត្រូវគ្នានឹង ុម ដូចជាពាក្យថា ក្រុំ ឬ ក្រុម ។

ស្រៈ ៃ ត្រូវនឹង ័យ ដូចជាសម័យ ។

## ព្យញ្ជនៈ

ព្យញ្ជនៈមាន ៣៣ តួគឺ ៖

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ

ឡ្ឡ ំ ។

ព្យញ្ជនៈចែកចេញជាពីរវគ្គៈ វគ្គ ១ អវគ្គៈ ១

វគ្គៈចែកចេញជា ៥ ពួកគឺ ៖

ក ខ គ ឃ ង ពួកទី ១

ច ឆ ជ ឈ ញ ពួកទី ២

ដ ឋ ឌ ឍ ណ ពួកទី ៣

ត ថ ទ ធ ន ពួកទី ៤

ប ផ ព ភ ម ពួកទី ៥

អវគ្គៈគឺសំដៅយកព្យញ្ជនៈ ៨ ពួកគឺៈ

យ រ ល វ ស ហ ឡ អ ។ អវគ្គៈ,

បណ្ឌិតខ្លះឲ្យឈ្មោះថាសេសវគ្គៈ ។

ព្យញ្ជនៈ គឺ ំ នេះហៅថា និគ្គហិត ឬអនុសារៈ ។

ព្យញ្ជនៈមានបែបសូរសំឡេងជាពីរគឺៈ ព្យញ្ជនៈមានសំឡេងធំក្រអៅឮសូរលាន់ពេញ ហៅថា ឃោសៈ, ព្យញ្ជនៈមានសំឡេងតូច មិនឮសូរលាន់ ហៅថា អឃោសៈ ។

ព្យញ្ជនៈអឃោសៈគឺ ក ខ ច ឆ ដ ឋ ត ថ ប ផ ស ហ ឡ ំ ។

ព្យញ្ជនៈឃោសៈគឺ គ ឃ ង ជ ឈ ញ ឌ ឍ ណ ទ ធ ន

ពគម យរលវ ។

ព្យញ្ជនៈ បើពិនិត្យតាមឋានថៃអក្ខរៈមាន ៦ គឺ:

១- កណ្ឋជៈ គឺព្យញ្ជនៈកើតក្នុងក: ក ខ គ ឃ ង ហ ។

២- តាលុជៈ គឺព្យញ្ជនៈកើតក្នុងពិតាន: ច ឆ ជ ឈ ញ យ ។

៣- មុទ្ធជៈ គឺព្យញ្ជនៈកើតក្នុងក្បាលៈ ដ ឋ ឌ ឍ ណ រ ឡ ។

៤- ទន្តជៈ គឺព្យញ្ជនៈកើតត្រង់ប្រទល់ធ្មេញ: ត ថ ទ ធ ន, ល ស ។

៥- ឱដ្ឋជៈ គឺព្យញ្ជនៈកើតក្នុងបបូរមាត់: ប ផ ព ភ ម ។

៦- នាសិកដ្ឋៈ គឺព្យញ្ជនៈកើតក្នុងច្រមុះគឺនិគ្គហិត ំ ។

ព្យញ្ជនៈ បើចែកមួយបែបទៀតមានពីរយ៉ាងគឺ:

១ - ព្យញ្ជនៈសិថិល

២ - ព្យញ្ជនៈធនិត

ព្យញ្ជនៈសិថិលគឺមានសំឡេងធូ, រលុង, ស្រាល, កគ, ចជ, ដឌ, តទ, បព ជាអក្សរមិនមានសូរអក្សរ ហ លាយផ្សំផង ។

ព្យញ្ជនៈ ធនិតគឺមានសំឡេងតឹង, ចង្អៀត, ធ្ងន់, ខឃ, ឆឈ, ឋឍ, ថធ, ផភ, ជាព្យញ្ជនៈដែលមានសូរ ហ លាយផ្សំផង ។

## សេចក្ដីពិនិត្យចំពោះព្យញ្ជនៈ

ព្យញ្ជនៈ បើមានមូសិកទន្តពីលើ (៉) គឺ អ៉ ទៅជា អ ដូចជា “អង” នឹង (អ៉ង) ។

ព្យញ្ជនៈ បើមានត្រីសព្ទពីលើ (៊) អ ទៅជា អ៊ ដូចជា “សក” នឹង “ស៊ក”, ស្រប នឹង ស្រ៊ប ។

ព្យញ្ជនៈ បើមានសំយោគសញ្ញា (័) ពីលើ, អ ទៅជា អ ដូចជា “សក” នឹងស័ក, “កន” នឹង “ក័ន” ។

ព្យញ្ជនៈ បើមានវណ្ណយុត (ុ) ពីក្រោម ដូចជាសីទៅជាសុី ហីទៅជា ហុី ។

## សំយុត្តស្រៈ

ដែលគេហៅថា សំយុត្តស្រៈ គឺស្រៈដែលមានសូរសំឡេងពីរ

ដែលគេស្ដាប់បានច្បាស់លាស់, ពិតមែនតែមានសំឡេងតែមួយ ។

សំយុត្តសរៈ គឺស្រៈ ឯ ឪ ។

ដូចជា ក្តែ, ត្រីគ្ដោ, ខ្វៃ ជាដើម

## ព្យាង្គ

ដែលហៅថាព្យាង្គ គឺសង្កត់ពាក្យ ។ ពាក្យមានមួយព្យាង្គ ឬច្រើនព្យាង្គ គឺ:

១– ឯកព្យាង្គ ដូចជាពាក្យថា: ផ្ទះ, នៅ, រស, ដី, បណ្ឌិតខ្លះហៅថា ព្យាង្គមួយ ឬមួយព្យាង្គ ឬព្យាង្គទោលក៏បាន ។

២– ទ្វេព្យាង្គ ដូចជាពាក្យថា: លំនៅ, សាលា, ព្យាយាម វិធី; បណ្ឌិតខ្លះហៅថា ព្យាង្គពីរ ឬពីរព្យាង្គ ។

៣– ត្រៃព្យាង្គ ដូចជាពាក្យថា: ព្រហ្មចារី, ពុទ្ធដំណើរ, គេហដ្ឋាន, ចន្ទ្រកំណើត; បណ្ឌិតខ្លះហៅថា: ព្យាង្គបី, បីព្យាង្គ, ត្រីព្យាង្គ ។

៤– ពហុព្យាង្គ គឺពាក្យតាំងពីបួនសង្កត់ឡើងទៅ; បណ្ឌិតខ្លះហៅថា: ព្យាង្គច្រើន, ច្រើនព្យាង្គក៏បាន ។

# អក្ខរៈ (ពាក្យកាព្យ)

<u>បទព្រហ្មគីត</u> – អក្សរស្នាមគំនូស ដែលចាំងឈូស

ពន់ផ្សេង ៗ សម្រាប់ប្រើខ្លីវែង សរសេរកត់
ពាក្យសំដី ៗ អក្សរគួរអប់រំ អ្នកតូចធំ
ទាំងប្រុស-ស្រី ព្យាយាមជាប្រក្រតី សាងបារមីជាតិ
ប្រសើរ ៗ ខំរៀនទើបបានចេះ ខំប្រឡេះ
ទាំងក្រោមលើ គោរពតាមដំណើរ អក្សរប្រើហាត់ឱ្យស្ទាត់ ៗ
ក្រោពត់ពីខ្ចី តាមប្រាជ្ញស្ដី ពាក្យទៀនទាត់
ឈើចាស់ពត់តែងក្លាត់ ប្ដូរប្រែះផ្លាត់ខូចអសារ ៗ
ពត់មនុស្សពត់ពីក្មេង បើវង្វេងស្រាំប្រែះធា
លែលកតាមប្រាជ្ញ ធំកាលណាមិនងាយស្ដី ៗ ព្យាយាមរៀនអក្សរ
យលខ្វាសទាំងប្រុសស្រ ពូជបេះផ្ទេរបេះក្ដី សព្វវែងខ្លីខំនេ្ទញ ៗ

## ស្រៈ

<u>បទកាគតិ</u> – ស្រៈជាអក្សរ បញ្ចេញសព្ទ សំឡេងខ្ទង់

នាំព្យញ្ជនៈ មានស្វរខ្លីវែង ប្រែកបញែកបែង

ម្តែមួយគូ ៗ ស្រៈមានពីរយ៉ាង ស្រៈពេញតួអាង

ដប់ប្រាំគាប់គួរ ស្រៈនិស្ស័យពិត ម្តែមួយគូ

ពិនិត្យដេញសួរ ក្នុងចិត្តសព្វគ្រប់ ៗ ស្រៈពេញតួកប

បែកចេញយលស្រប ពីរយ៉ាងប្រសប់ រស្សៈស្វរខ្លី

រៀនកុំធុញថប់ ទីឃៈបញ្ចប់ ស្វរវែងតាមក្បួន ៗ

ស្រៈនិស្ស័យចាត់ ប្រែកបកាច់កាត់ មានពីរគាប់ជួន

រស្សៈទីឃៈ សិក្សាមាំមួន ឲ្យស្គាល់រូបខ្លួន

ភាពបែបអក្ខក ៗ

## ព្យញ្ជនៈ

បទពាក្យ៩ –ព្យញ្ជនៈ សាមសិបមី គួរបែបបទ

បែកបែងកត់ ជាវគ្គៈ ញែកពួកប្រាំ

អវគ្គៈ ព្យញ្ជនៈ ប្រាំបីចាំ

ព្យាយាមមាំ សេសវគ្គៈ ឲ្យនាមា ៗ

| | | |
|---|---|---|
| ព្យញ្ជនៈ | ភាពបែបនេះ | ហៅនិគ្គហិត |
| គេហៅពិត | ប្រែកពីដើម | អនុសារ |
| ព្យញ្ជនៈ | សំឡេងធំ | ហៅឃោសៈ |
| តូចស្ទួ | មិនសូវណាន់ | អឃោសៈ ។ |
| ព្យញ្ជនៈ | គួរពិនិត្យ | ឋានអក្សរ |
| ប្រាំមួយ ៖ | កើតក្នុងក | កណ្ឋជៈ |
| ក្នុងពិតាន | ហៅសន្ទត | តាលុជៈ |
| មុទ្ធជៈ | កើតក្នុងក្រាល | តាមបែបបទ ។ |
| ទន្តជៈ | កើតចំពោះ | ប្រទល់ធ្មេញ |
| សូរបញ្ចញ | ឱដ្ឋជៈ | ប្រកបកត់ |
| ត្រង់ប្រទល់ | បបូរមាត់ | ដោយសន្ទត |
| តាមកំណត់ | នាសិកជ្ជ | ក្នុងប្រមុះ ។ |
| ព្យញ្ជនៈ | សំឡេងធូរ | ហៅសិថិល |
| ចំរមិល | មើលឲ្យយល់ | សព្ទឡើងចុះ |
| ពួកធនិត | សំឡេងតឹង | ស្គាល់ត្រូវខុស |

រៀនចាក់ធ្លុះ ឲ្យយល់សព្វ កុំឲ្យសល់ ។

ពាក្យសួរៈ អ្វីដែលហៅថា អក្ខរៈ ឬអក្សរ? អក្ខរៈមានប៉ុន្មានយ៉ាង?

អ្វីដែលហៅថាស្រៈ? ស្រៈមានប៉ុន្មានតួ? ស្រៈមានប៉ុន្មានយ៉ាង? ចូរអធិប្បាយ ។

បើតាមពិនិត្យនូវស្រៈ, តើមានប៉ុន្មានបែប អ្វីខ្លះ?

ព្យញ្ជនៈ មានប៉ុន្មានតួ? តើមានប៉ុន្មានវគ្គ? បើចែកជាពួក មានប៉ុន្មានពួក?

អ្វីដែលហៅថាអនុសារៈ

ព្យញ្ជនៈ ចែកតាមប្រភេទ, ឋានៈអក្ខរៈ, សូរសំឡេងមានប៉ុន្មានយ៉ាង ចូរអធិប្បាយ? ការពិនិត្យនូវព្យញ្ជនៈមានប៉ុន្មានយ៉ាង? សំយុត្តសរៈបានន័យថាដូចម្ដេច ?

អ្វីដែលហៅថាព្យាង្គមានប៉ុន្មានយ៉ាង?

# ៤_ វណ្ណយុត្តិ

អ្វីដែលហៅថាវណ្ណយុត្តិ? វណ្ណយុត្តិ គឺគ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្ខរៈ ឬអក្សរ ។

វណ្ណយុត្តិ សម្រាប់ប្រើក្នុងភាសាខ្មែរមាន ២១ គឺ:

១.- វិសជ្ជនីយ៍ (ះ): វណ្ណយុត្តិនេះ បើខាងអក្សរសំស្រ្កឹត, ប្រើជាចំណុច ១ គូសលើក្រោមដូចយុគលពិន្ទុ (:) មានសូរសំឡេងស្រដៀងអក្សរ ស, តែមិនចេញសូរសម្ពស្ស តាមប្រទល់ច្នេញ ដូចតួ ស ទេ ដូចជា កន្ទុះ, ពោះ, ខុសសូរសំឡេងនឹងពាក្យថា កន្ទាស់, ពស់ ។

ពាក្យសំស្រ្កឹត ដែលមាន ហ នៅខាងចុង បើផ្លាស់ ហ ជា វិសជ្ជនីយ៍ (ះ) មិនត្រូវប្រើតួ ហ ថែមទៀតទេ, ដូចជា: គុហ, ចន្ទ្រគុហ, សំគ្រហ៍ ទៅជា គុះ ឬ គ្រឹះ, បន្ទ្រោះ. សង្គ្រោះ ។

វិសជ្ជនីយ៍ ខ្លះហៅថារះមុខ ឬវិសគ៌ ក៏បាន ។

២- មូសិកទន្ត ("): វណ្ណយុត្តិនេះមានរូបជាគំនូសក្បៀស

ពីរ សម្រាប់ប្រើសម្គាល់បំបែរសំឡេងព្យញ្ជនៈ៩ តួ គឺៈ ង, ញ, ន, ប, ម, យ, រ, ល, វ ឲ្យទៅជាសំឡេងថា ង៉, ញ៉, ន៉, ប៉, ម៉, យ៉, រ៉, ល៉, វ៉ ។

វណ្ណយុត្តិនេះសម្រាប់ប្រើដាក់លើស្រៈ ិ ឲ្យជា ិ៍ក៏បាន ។ អ្នកប្រាជ្ញខ្លះហៅវណ្ណយុត្តិនេះថា “ធ្មេញកណ្ដុរ” ។

៣– ត្រីសព្ទ (៊): វណ្ណយុត្តិនេះសម្រាប់ប្រើដាក់លើអក្សរបួនតួ គឺៈ ប, ស, ហ, អ, ឲ្យ មានសំឡេងជា ប៊ ស៊, ហ៊, អ៊, ដូចពាក្យថា ប៊ុន, ប៊ិន, ប៊ិត, ស៊ីនសំដី, ព្រុស្បូរស៊ិន, ហ៊ាន និយាយ, ពួកហ៊ុន, ដំណើរអ៊ីកអ៊ិក ជាដើម ។

តែតួ ស កាលណាបើមានស្រៈឥ ឬ ឦ នៅខាងលើ ទីងផ្លាស់រូប (៊) នេះចេញ ដូចជា ស៊ីបាយ ។

៤ – ទណ្ឌឃាត (៍) ខ្មែរយើងប្រើពាក្យនេះជាឈ្មោះវណ្ណ-យុត្តមួយដែលមានសណ្ឋានលំទំាកន្ទុយកំប្រុក (៍) សម្រាប់ដាក់ឃាត់អក្សរមិនឲ្យមានសំឡេង, ដូចជាប្រយោជន៍, យោជន៍, ខ្ញុំមបន្ទន៍, ស្ពាប់ទេសន៍ មហាក្សត្រិយ៍, គាជន៍ ជាដើម ។ វណ្ណ-

យុត្តនេះ, អ្នកប្រាជ្ញខ្លះហៅថា បដិសេធក៏បាន;

៥- របាទ ( ៌ ) ជាឈ្មោះវណ្ណយុត្តមួយ យ៉ាងសម្រាប់ប្រើ ដាក់លើអក្សរតួចុង ឲ្យអក្សរតួដើមបន្ទាប់នោះមានសូរសំឡេងញ័រ, ប្រើចំពោះតែភាសាខ្មែរដែលមកពីភាសាសំស្រ្កឹត ឬ សំស្រ្កឹតក្លាយ ដូចជាពាក្យថា: គភ៌, ទុគ៌ត, ទុព៌ត, ធម៌, បព៌ត, ព័ណ៌, អាថ៌ ជាដើម ។

បើមានស្រៈដែលទើសពីបាកសរសេរនោះត្រូវដាក់ រ ពេញតួ ពីលើដើមអក្សរខាងចុងវិញ, ដូចជា: ទុរ្ភិក្ស, មូរ្តី, ពមគ្រ័, ត្រីយ ជាដើម ។

ប៉ុនកាលមិនមានស្រៈទើសទែងទេ ប៉ុន្តែគួរឲ្យប្រឡំពីបាកអាន ក៏ត្រូវដាក់តួ រ លើដើមអក្សរខាងចុងដែរ ដូចជាពាក្យថា: កម៌ន, អស្ចាយ៌, អាចាយ៌ ត្រូវដាក់ជាគន្ទ អស្ចារ្យ អាចារ្យ បើមានអក្សរ រ ខាងចុង មិនត្រូវប្រើរបាទទេ ដូចជាពាក្យ: ជ័រ: សង្ស័រ ញ័រ: ទ័រ ។

របាទនេះ បណ្ឌិតខ្លះហៅថា រេផៈ ក៏បាន; បើតាមពិតគួរឲ្យ

ជ្រៅវែងឆ្ងាយទៅ, វណ្ណយុត្តរបាទ ឬ រេផៈ ជាដើមអក្សរ ។

៦= រស្សសញ្ញា ( ' ) ខ្មែរប្រើវណ្ណយុត្តនេះមានសណ្ឋាន កំបុតខ្លី សម្រាប់ប្រើបំបែរសំឡេងវែងឲ្យខ្លីកំបុតជួន, បើដាក់បាន ចំពោះតែពីលើតួអក្សរ ប្រកបរបស់ពាក្យខ្មែរដែលជាស្រះ អ.អា, ពីរនេះ, ដូចជា អត់, កក់, ចប់; ដល់ អាន់, កាន់, ទាន់, ជាន់, ពាល់ ជាដើម ។

រស្សសញ្ញា, បណ្ឌិតខ្លះហៅថាសង្កត់ ឬបន្តក់ក៏បាន; ភាសាថៃហៅថាម៉ៃឯក (ម៉ៃអេក ប្រែថាឈើមួយ) ។

៧– សំយោគសញ្ញា (ˇ) ខ្មែរប្រើវណ្ណយុត្តិនេះសម្រាប់ថា ជំនួសអក្សរសំយោគ សម្រាប់លំអៀងស័ព្ទភាសាបាលី ឬសំស្រ្កឹត មកជាភាសាខ្មែរ ឬសម្រាប់ដាក់លើពាក្យមគធៈ ឬសំស្រ្កឹត ពួកខ្លះ ដែលប្រើបំប្លែងសំឡេងឲ្យក្លាយល្អៀងពីសូរដើម, កាលបើមិន ដាក់ (ˇ) នេះនាំឲ្យពិបាកពោល, ដូចពាក្យៈ ក្សយ ជាក្ស័យ, ជយ ជាជ័យ, នយ ជាន័យ, ភយ ជាភ័យ, បច្ចយ ជាបច្ច័យ, អនាមយ ជាអនាម័យ, សមយ ជាសម័យ ។

សំយោគសញ្ញានេះ សម្រាប់យកមកប្រើនៃពាក្យខ្មែរខ្លះថា : ខ្ញ័រ, ជ័រ ញ័រ, ទំព័រ, សន្ស័រ ទំប័ង ជាដើម ។

បើពាក្យដែលមានអក្សរសំយោគហើយ ប៉ុន្តែបើមិនដាក់(៉)នេះផ្សំផងទេ នាំឲ្យពិបាកថា, ត្រូវប្រើវណ្ណយុត្តិនេះថែមទៀត, ដូចជាពាក្យ: ព័ន្ធ, ក័ព្វ, ម្រ័ក្សណ៍, យ័ន្ត, ល័ក្ខ ជាដើម ។

វណ្ណយុត្តិនេះជួនកាលយកទៅប្រើនឹងភាសាបរទេសក៏មាន, ដូចជា លោកឌីរិកទ័រ, លោកអ័ន្សិកទ័រ, លោកកុងត្រូល័រ ជាដើម ។

៨– កាមេណ្ឌិតសញ្ញា (ៗ) វណ្ណយុត្ត នេះខ្មែរយកមកប្រើសម្រាប់សរសេរពីខាងមុខពាក្យដែលត្រូវថាជួន ដូចជាពាក្យ- ផ្សេងៗ, ទីទៃៗ, បងៗ, ច្រើនៗ ជាដើម ។

កាមេណ្ឌិតសញ្ញា បានន័យថា ដែលជួនពីរដង, ដែលជួនៗ, បណ្ឌិតខ្លះហៅថាលេខទោ ។

៩– លេខអស្តា (៏) ឈ្មោះវណ្ណយុត្តមួយបែបសម្រាប់ដាក់លើអក្សរពោល នាំឲ្យអក្សរនោះមានសំឡេងកញ្ចក់ខ្លីរហ័ស ដូចជា ក៏បាន, ក៏ដែរ, ក៏ដោយ, ដ៏បវរ, ព្ងដ៏ព្រៃ, អញ្ចឹង, បណ្ឌិតខ្លះ

ហៅថា អស្តាលេខក៏បាន ។

១០– កាកបាទ (+) វណ្ណយុត្តមួយយ៉ាងមានសណ្ឋានដូចជើងក្អែក សម្រាប់ប្រើអក្សរដែលសរសេរខុស ហើយសរសេរទៀតពីលើ ឬពីក្រោមត្រូវការ ជើងក្អែកនេះ ដូចជា ខ្ញុំ

បំណង ទិញ
មាន + ចង់ទៅផ្សារក + អាហារ ។

ក់នៅ
គេហដ្ឋានខ្ញុំបានស្នា + ៣០ វិថីប៉ាស្ទ័រ ។

កាកបាទនេះ មានបណ្ឌិតខ្លះហៅថាជើងក្អែកក៏បាន ។

១១– កុក្កុដនេត្រ (៙): ឈ្មោះវណ្ណយុត្តមួយយ៉ាងមានរាងមូលពីរជាន់តូចក្នុងធំក្រៅសណ្ឋានស្រដៀងនឹងភ្នែកមាន់ សម្រាប់ប្រើសរសេរដាក់ត្រង់ក្បាលបន្ទាត់ដើមសេចក្តីធំមួយ ៗ (៙) តែក្នុងសម័យសព្វថ្ងៃនេះមិនសូវប្រើ ។

វណ្ណយុត្តនេះ មានខ្លះហៅថា ភ្នែកមាន់ក៏បាន ។

១២– ល្បះ (។): វណ្ណយុត្តនេះសម្រាប់ប្រើរះពាំងឃ្លា ឬសង្កាត់សេចក្តីមួយ ៗ ឲ្យដាច់ស្រឡះដោយឡែកដូចជាពាក្យថា: រះ

ល្បះ, សរសេរអក្សរគ្មានល្បះ ។

បើតាមទំនងពាក្យ, គួរសរសេរជារបះ ព្រោះជាអំពើរបស់រះ ប៉ុន្តែមិនដែលឃើញប្រើ ។

ល្បះមានល្បះតូច, ល្បះធំ, ល្បះបន្ទាត់ឬល្បះលូកបន្ទាត់និងបរិយោសាន ។

ល្បះតូច គឺល្បះខ្លី គឺល្បះដែលរះកំងសេចក្ដីខ្លី ;

ល្បះធំ គឺ ល្បះវែងគឺល្បះដែលរះកំងសេចក្ដីវែង ;

ល្បះបន្ទាត់គឺល្បះដែលរះនៅបន្ទាត់មួយខាងលើហើយ ត្រូវសរសេរត្រង់បន្ទាត់មួយខាងក្រោមបន្ទាត់នោះលូកចូលមកក្នុងបន្តិច

ល្បះបរិយោសានគឺល្បះចប់ ។

១៣ – ល្បះ បរិយោសាន (។): ល្បះមានរូប ៣ បែបគឺ (។|)១, (។៚)១, (។| ៚)១ សម្រាប់រះបញ្ចប់សេចក្ដីដែលហើយត្រឹមប៉ុណ្ណោះ ។

ល្បះនេះខ្លះឲ្យឈ្មោះថាល្បះចប់កថាន ។

១៤ – គោមូត្រ (៚): វណ្ណយុត្តនេះមានសណ្ឋាន

ស្រដៀងនឹងកន្ទាញ់ទឹកនោមគោ សម្រាប់ប្រើសរសេរដាក់ត្រង់កន្ទុយបញ្ចប់សេចក្ដីដែលចប់ អស់ហើយត្រឹមតែប៉ុណ្ណោះ ។

១៤– កាក់ឬគាប ( } ) ឈ្មោះវណ្ណយុត្តសម្រាប់សរសេរគាបពាក្យទន្ទឹមគ្នា ដូចជាថ្ងៃ ៨ កើត } ។
រោច

១៦ – វគ្គសញ្ញា (–) សម្គាល់ពាក្យមួយម៉ាត់ដែលបំផ្ដាច់ចេញអោយខ្ទង់ពីគ្នាត្រង់ចន្លោះគាថា, កាព្យ, ឃ្លោង ដូចជា,

ប្រុសស្រីម- ហាជនកប ហាត់សូត្ររៀន
កុំអៀនប្រៀន សិក្សាវិ- ជ្ជាលោកធម៌ ។

វណ្ណយុត្តនេះ មានខ្លះឈ្មោះថា យតិភង្គ ក៏បាន ។ យតិភង្គ បានន័យថា ដំណើរឈប់បង្អង់តាមឃ្លាគាថា, កាព្យ, ឃ្លោង គឺសម្គាល់ឃ្លាមួយ ៗ ។

១៧– មច្ឆណ្ណសញ្ញា (.....) វណ្ណយុត្តនេះសម្រាប់ប្រើដាក់ក្នុងការបាត់បញ្ចាក់ ដូចជា ........ ទៅកំសត់អើយ ..... ចោរកំណាចចាំងឡាយ; ស្ត្រីនាមនាង..... មានរូបរាងស្អាត; ចោរនៅព្រៃ...... កំពុងតែលាក់ពួនខ្លួន ។

នាយសួនចៅកំសត់អើយ  អាពួកចោរកំណាចទាំងឡាយ
ស្ត្រីនាមនាងសុទ្ធមានរូបកងស្អាត; ចោរនៅព្រៃសន្ធរកំពុងលាក់
ពួនខ្លួន ។

មច្ឆណ្ណាសញ្ញា នេះសម្រាប់ខាងទុះទានសព្ទ ដូចជា ៖

ផង! ផង..... ព្រួសកំភ្លើងបាញ់ក្នុងព្រៃ

ឱពុទ្ធោអើយ ......... ខ្ញុំបំជាកម្រាស់,

អនិច្ចា...... ឱគួរឲ្យអាណិតណាស់

សញ្ញានេះមានខ្លះហៅថាពងត្រី ។

១៨ – បេយ្យាល ( ។ បេ ។ ) ឬ ( ។ ល ។ ): វណ្ណយុត្ត នេះសម្រាប់ប្រាប់ថាពាក្យដែលគេរាប់រៀបនោះមិនទាន់អស់ទេ នៅមានតទៅទៀត គឺសម្រាប់ប្រើបំប្រួញសេចក្តីវែងឲ្យខ្លី ឬប្រើនឲ្យតិច ប្រើតែអក្សរ ១ តួខាងដើមថា ។បេ។ ឬថា(បេ៉)ក៏បានឬប្រើតែអក្សរខាងចុងថា ។ល។ (ល៉ះ) ដូចជា:

កូនសិស្សត្រូវមានសៀវភៅសរសេរ, សៀវភៅអាន, ទឹក

ទៅ, ដងប៉ាកកា . . . . ។ល។

១៩ – យុគលពិន្ទុ ( : ): ជាវណ្ណយុត្តម្យ៉ាងសម្រាប់ប្រើ ចុចសំលេងពាក្យឲ្យស្រាយថា ដូចជា,

សរៈ ធុរៈ ការៈ ព្យូហៈ លក្ខណៈ សោកៈ ជាដើម ។

២០ – អព្ភន្តរសញ្ញា “ . . . . ” ; វណ្ណយុត្តនេះសម្រាប់ ប្រើដើម្បីបញ្ជាក់ដល់អ្នកអានឲ្យចំពិនិត្យ ព្រោះជាសេចក្តីសំខាន់ៗ

កិច្ចការប្រជុំនេះត្រូវមកកុំខាន “ មានប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំ- ពោះជាតិ, សាសនា, មហាក្សត្រ ” ហើយយើងនឹងសន្ទនាគ្នាតែហេតុផលឲ្យឃើញជាក់លាក់ ។

២១ – វង់ក្រចក ( . . . . ): វណ្ណយុត្តនេះសម្រាប់ ដាក់គាប់ពាក្យណា ឬ ឃ្លាណាមួយដែលមិនមានទាក់ទង, ចូលក្នុងអត្ថបទនោះទេ, ត្រូវនឹងវណ្ណយុត្តបាំងថា ប៉ារ៉ង់តែស ( Paren- thèse) សម្រាប់ប្រើបំពាំង សេចក្តីដែលមានដំណើរដោយឡែក ដូចជា,

ទីក្រុងព្រៃនគរ (ប្រទេសយៀកណាមខាងត្បូង) ជាកំពង់

សំបុត្រនាំផ្ញើ ៗ មកពីបរទេស ។

ការិយាល័យ (ប៊ុយរ៉ូ) ឃោសនាការ មានច្រើន ។

ចំនួនប្រាក់មួយពាន់រៀល (១០០០៛ ០០) ។

ក្រៅពីនេះ គេតែងយកវណ្ណយុត្ត, បារាំងមកប្រើខ្លះដែរ ដូច

ជា , ; . ? ! ជាដើម ។

## វណ្ណយុត្ត (បទកាកគតិ)

វណ្ណយុត្តមួយ ជាគ្រឿងជំនួយ ដល់ពាក្យអក្ខរៈ

ប្រើផ្សំតាមភាព ភាសាខេមរៈ តាមព្យញ្ជនៈ

ឬស្រៈគួរការ ៗ វិសជ្ជនីយ៍ (ះ) សូរសព្ទពេញទី

ទុកជាខ្លឹមសារ អក្សរសខ្យល់ បូរអ្នកចាំចារ

កង ហតុយា កុំឲ្យភ្លេចបាន ៗ មូសិកទន្ត (៉)

សម្រាប់គេគាន់ សម្លាប់រូបប្រាណ បំបែរសំឡេង

ព្យញ្ជនៈមាន ប្រាំបួនគត្ថាន ខ្យល់អូជាអ ។

ត្រីសព្ទ(៊) វណ្ណយុត្ត សម្រាប់ប្រាកដ ដាក់លើអក្សរ

បួនតួកបក្ខ ប, អ ស, ហ ;

ឲ្យយល់ខ្មៅស ខន្ទញឲ្យចាំ ៗ ខណ្ឌឃាតវណ្ណយុត្ត (៤)
មានស្ពានបរិសុទ្ធ លោកគ្រូណែនាំ កន្ទុយកំប្រុក
ឃាត់អក្សរម៉ាំ ព្យាយាមថែទាំ មិនឲ្យមានសូរ ៗ
វណ្ណយុត្ត របាទ (៥) បណ្ឌិតប្រើខ្នាត
វិធីផ្លាស់ប្តូរ ដាក់លើតួបុរី អក្សរដើមដូរ
សំឡេងញ័រគូរ កម្រើកដើមទ្រូង ៗ រស្សៈសញ្ញា (៦)
បំបែរអក្ខរ សំឡេងវែងខ្លួន សព្វទីបំផុត
គួរចាំបេះដូង ឈើមួយគ្មានគោង សង្កត់បន្តក់ ៗ
សំយោគសញ្ញា (៧) មូលមកអក្ខរ លំអៀងតួបសក់
ភាសាបាលី សំស្ក្រឹតបោកបក់ ភាសាខ្មែរផក់
មគធៈតាមការ ៗ បំប្លែងសំឡេង សូរខ្ចីទៅវែង
ល្អៀងសូរអស្ចារ្យ ពីសូរសព្ទដើម ប្រើពាក្យអក្ខរ
បរទេសភាសា គួរយើងចងចាំ ៗ អាមេណ្ឌិតសញ្ញា (៨)
សរសេររៀនតាគ្នា ខានមុខផ្ទួនទាំ ផ្សេង ៗ ទីទៃ
ចំរៀនមួនមាំ ព្យាយាមគ្រូផ្ដាំ ខ្នះហៅលេខទោ ៗ

ឯលេខអស្តា (៨)  ធ្វើសូរអក្ខរា  សំឡេងពេញពោ
កញ្ឆក់ហើយខ្វី  រហ័សទឹកដៅ  លាន់ឮគាប់គួរ
ក៏មានបែបបទ ៗ  កាកបាទវណ្ណយុត្ត(+)  អក្សរឆាប់ផុត
សរសេរខុសគត់  ជ្រៀតពីលើក្រោម  បណ្ឌិតសន្មត
ប្រកបប្រាកដ  ហៅថាជើងក្អែក ៗ  កុក្កុដនេត្រ (១)
វណ្ណយុត្តតាមគេច  សង្កេតយល់ខ្វែក  ប្រើដាក់បូរាណ
ក្បាលបន្ទាត់បែក  ដើមសេចក្ដីបែក  បច្ចុប្បន្នមិនប្រើ ៗ
ខ្វះហៅក្អែកមាន់  វង់មូលពីរជាន់  តូចកុងមូលលើ
បណ្ឌិតសម័យ  ធំក្រៅប្រាជ្ញធ្វើ  មិនឃើញយកប្រើ
បូរបាតិទិត្យ ៗ  វណ្ណយុត្តហៅល្បះ  ( ៗ )
សម្រាប់ប្រើរះ  កំងឃ្លាគួរគិត  សង្កាត់សេចក្ដី
ដាច់ស្រឡះពិត  មួយ ៗ ឆ្ងាយជិត  ល្បះតូចល្បះធំ ៗ
មានល្បះបន្ទាត់  គាប់កបលះកាត់  ល្បះយោងឃ្លាសម
ល្បះលូកបន្ទាត់  ល្បះហៅប្រមុំ  បរិយោសុខុម
អវសានខាងចុង ៗ  បរិយោសាន  ខ្វះឲ្យនាមប្រាណ

ពូជល្បះចប់ពន្យ សម្រាប់បញ្ចប់ សេចក្តីភាពវែង
ឲ្យយល់គេទទ្រន់ សេចក្តីគួរគាប់ ។ គោមូត្រ ( ៚ )
វណ្ណយុត្ត នាមហៅមោះមុត ដាក់កន្ទុងជាប់
បញ្ចប់សេចក្តី ដែលចប់រៀបរាប់ លែងពោលសួរសព្ទ
ស្ងាត់ត្រឹមប៉ុណ្ណោះ ។ វណ្ណយុត្តិហៅកាត់ ( ⟩ ) សម្រាប់ប្រើកាត់
សរសេរគាបពាក្យ ទន្ទឹមគ្នាស្មេះ ខ្ចះហៅ “ គាប ” ផ្អាក
រឿងរឿមមិនដាក់ លែងផ្អាកខ្លួនរួច ។ រដ្ឋសញ្ញា ( – ) :
វណ្ណយុត្តិនេះណា សម្រាប់ភ្ជាប់គួប សង្កាត់ពាក្យឃ្លាន
ផ្តាច់ចេញតិចតួច មានផលប្រយោជន៍ ហៅយតិកគ្គ ។
មច្ឆណ្ឌសញ្ញា ( . . . ) ដែលមានរូបា ចុចច្រើនផ្លូវឃាំង
បញ្ជាក់ឲ្យច្បាស់ សម្រាប់ពកំង ឃ្លាដកសម្រាំង
ប្រើទុក្ខានសព្ទ ។ វណ្ណយុត្តិបេយ្យាល ( ។ បេ ។ )
( ។ ល ។ ) ត្រូវប្រើតាមកាល សេចក្តីចង់ចាប់
បំប្រួញឲ្យខ្លី ដំណើរវែងគាប់ សេចក្តីច្រើនជាប់
ជាតិចវិញបាន ។ យុគលពិន្ទុ ( : ) សម្រាប់ប្រើចុច

សម្រួលរូបប្រាណ ពាក្យឲ្យឆាយថា ទៅតាមភាពស្ថាន
និស្សិតកល្យាណ រៀនគូសបង់ចាំ ៗ អត្តនេសញ្ញា “...”
វណ្ណយុត្តិនេះណា សម្រាប់ណែនាំ បញ្ជាក់អ្នកអាន
ឲ្យយល់មួនមាំ រឿងសំខាន់សម ត្រូវតែពិនិត្យ ។
ឯវង់ក្រចក (.....) សម្រាប់ដាក់បក ពាក្យឃ្លាឃ្លាងពិត
មិនមានទាក់ទង ឬប្លែកគំនិត ពីអត្ថបទគិត
តាមភាពគួរគាប់ ៗ វណ្ណយុត្តិភាព ម្តែមួយប្រាប់
ចូរឲ្យចាំជាប់ សម្រាប់ពិនិត្យ វេយ្យាករណ៍ភ្ជាប់
ព្យាយាមគួរគាប់ បេះប្រែកបកាល ៗ ចាំតាមឃ្លោងឃ្លា
ចូររៀបពប់គ្នា តាមទម្លាប់ស្រាល វគ្គសេចក្តីជូន
ដកឃ្លាស្រយាល ដម្រូវតាមកាល សួរសព្ទសំឡេង ៗ

<u>ពាក្យសួរ</u> – អ្វីដែលហៅថាវណ្ណយុត្ត? វណ្ណយុត្តសម្រាប់ប្រើក្នុងភាសាខ្មែរមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

វណ្ណយុត្ត វិសជ្ជនីយ៍ មានទ្រង់ទ្រាយយ៉ាងណាសម្រាប់ប្រើបែបណាខ្លះ? ពាក្យសំស្ក្រឹតដែលមានតួ ហ នៅខាងចុង បើផ្លាស់ ហ

ជាវិសជ្ជនីយ៍(ះ) តើត្រូវប្រើតួហ ថែមទៀតឬ? ចូរលើកឧទាហរណ៍!

តើវណ្ណយុត្តិ វិសជ្ជនីយ៍ មានហៅអ្វីខ្លះទៀត ។

យ៉ាងដូចម្ដេចដែលហៅថាមូសិកទន្ត? មានសភាពបែបណា? វណ្ណយុត្តិសម្រាប់ប្រើយ៉ាងណាខ្លះ? អ្នកប្រាជ្ញខ្លះហៅវណ្ណយុត្តិនេះ យ៉ាងណាខ្លះ?

វណ្ណយុត្តិ ត្រីសព្ទ បានន័យថាយ៉ាងណា? មានទ្រង់ទ្រាយបែបណា? វណ្ណយុត្តិនេះសម្រាប់ប្រើលើអក្សរណាខ្លះ? ឧទាហរណ៍... ។ តែតួស កាលណាបើមានស្រះ ឥ ឬ ឦ នៅខាងលើ តើនឹងត្រូវផ្លាស់វណ្ណយុត្តិនេះចេញឬ? ឧទាហរណ៍! ។

អ្វីដែលហៅ ទណ្ឌឃាត? វណ្ណយុត្តិនេះមានរូបទ្រង់ទ្រាយ យ៉ាងណាខ្លះ? សម្រាប់ប្រើបែបណាខ្លះ? អ្នកប្រាជ្ញខ្លះគេហៅថា អ្វី? ឧទាហរណ៍!

ពាក្យថា របាទ បានន័យថាយ៉ាងណា? វណ្ណយុត្តិ របាទ សម្រាប់ប្រើយ៉ាងណាខ្លះ? មានរូបទ្រង់ទ្រាយបែបណា? ឧទាហរណ៍ បើមានស្រះទើសពិបាកសរសេរនោះ ត្រូវដាក់អក្សរអ្វី?

ឧទាហរណ៍ ជួនកាលមិនមានស្រៈទើសទែងទេ ប៉ុន្តែគួរឲ្យច្រឡំ ពិបាកអាន តើត្រូវធ្វើដូចម្ដេច? ឧទាហរណ៍ ។

វណ្ណយុត្តរស្សសញ្ញានេះ បានន័យថាយ៉ាងណាខ្លះ? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើបែបណា? ឧទាហរណ៍ ។

រស្សសញ្ញានេះ បណ្ឌិតខ្លះហៅថាអ្វី? បើត្រូវនឹងវណ្ណយុត្តភាសាថៃឈ្មោះអ្វី?

វណ្ណយុត្ត សំយោគសញ្ញា បានន័យថាយ៉ាងណាខ្លះ? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើបែបណា? ឧទាហរណ៍

សំយោគសញ្ញានេះ សម្រាប់យកមកប្រើនៅពាក្យខ្មែរខ្លះបានឬទេ? ឧទាហរណ៍... ។

ឯពាក្យដែលមានអក្សរសំយោគហើយ ប៉ុន្តែបើមិនដាក់វណ្ណយុត្តសំយោគនេះផ្សំផងទេនាំឲ្យពិបាកថា តើត្រូវប្រើវណ្ណយុត្តនេះថែមទៀតឬមិនប្រើ? ឧទាហរណ៍-

វណ្ណយុត្តសំយោគសញ្ញានេះ បើយកទៅប្រើក្នុងភាសាបរទេសបានឬទេ? ឧទាហរណ៍-

វណ្ណយុត្តមេណ្ឌិតសញ្ញា បានន័យយ៉ាងណា? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើយ៉ាងណាខ្លះ? សូមពន្យល់ដោយឧទាហរណ៍ ។

វណ្ណយុត្តនេះ បណ្ឌិតខ្លះឱ្យឈ្មោះថាអ្វី?

លេខអស្តា តើមានន័យថាដូចម្តេចខ្លះ? មានរូបទ្រង់ទ្រាយយ៉ាងណា? សម្រាប់ប្រើបែបណាខ្លះ? សូមពន្យល់ដោយឧទាហរណ៍ ។

វណ្ណយុត្តនេះ បណ្ឌិតខ្លះហៅថាអ្វី?

កាកបាទ តើមានសេចក្តីថាយ៉ាងណា? មានសណ្ឋានទ្រង់ទ្រាយយ៉ាងណា? គួរប្រើបែបណា? សូមពន្យល់ដោយឧទាហរណ៍ ។

បណ្ឌិតខ្លះឱ្យឈ្មោះវណ្ណយុត្តថាជាអ្វីទៀត?

កុក្កុដនេត្រ តើបានន័យថាយ៉ាងណា? មានភាពរូបយ៉ាងណា? សម្រាប់ប្រើបែបណា?

វណ្ណយុត្តនេះគេប្រើមកលុះសព្វថ្ងៃឬ? អ្នកប្រាជ្ញខ្លះហៅវណ្ណយុត្តនេះថាជាអ្វីទៀត? -

អ្វីដែលហៅថាល្បះ? មានរូបទ្រង់ទ្រាយយ៉ាងណាខ្លះ?

ចូរអ្នកឆ្លើយអំពីសមភាពនៃល្បះ? តើសម្រាប់ប្រើយ៉ាងណា?

អ្វីហៅថាល្បះបរិយោសាន? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើយ៉ាងណា? អ្នកប្រាជ្ញទាំងឡាយហៅវណ្ណយុត្តថាអ្វីទៀត?

គោមូត្រ បានន័យថាយ៉ាងណា មានសណ្ឋានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើយ៉ាងណាខ្លះ? ចូរពន្យល់ដោយឧទាហរណ៍ ។

រផ្ទុសញ្ញា បានន័យថាយ៉ាងណា? មានសណ្ឋានរូបទ្រង់ទ្រាយបែបយ៉ាងណា? សម្រាប់ប្រើយ៉ាងណា?

អ្នកប្រាជ្ញខ្លះហៅវណ្ណយុត្តនេះថាអ្វីទៀត?

វណ្ណយុត្តមច្ឆណ្ឌុសញ្ញា បានសេក្តីយ៉ាងណា? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើយ៉ាងណា?

មច្ឆណ្ឌុសញ្ញា សម្រាប់ប្រើបែបណាទៀត? ឧទាហរណ៍ ។ ខ្លះគេហៅថាអ្វី?

អ្វីដែលហៅថា បេយ្យាល? គេសរសេរបែបណា? សម្រាប់

ប្រើយ៉ាងណាខ្លះ?

ពាក្យថាយុគលពិន្ទុ បានន័យថាយ៉ាងណា? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើបែបណា?

ពាក្យថាវង់ក្រចក ដាវណ្ណយុត្តមានរូបទ្រង់ទ្រាយយ៉ាងណា? សម្រាប់ប្រើបែបណាខ្លះ? ចូរពន្យល់ដោយឧទាហរណ៍ ៗ

អត្ថន្តរសញ្ញា បានន័យថាយ៉ាងណា? មានរូបទ្រង់ទ្រាយបែបណា? សម្រាប់ប្រើយ៉ាងណា? ចូរអធិប្បាយដោយឧទាហរណ៍មកបញ្ជាក់ ៗ

# វេយ្យាករណ៍

អ្វីដែលហៅថា "សេចក្ដី" : សេចក្ដី គឺការរួបរួមប្រយោគផ្សេង ៗ ដែលមានក្នុងភាសាមនុស្ស ។

ដំណើរពាក្យដែលមានសេចក្ដីគ្រប់គ្រាន់មួយសង្កាត់ ៗ ហៅថាប្រយោគ; ច្រើនព្យាង្គហៅថាប្រយោគ; ច្រើនប្រយោគហៅថាសេចក្ដី, រួបរួមសេចក្ដីហៅថា សង្កាត់សុន្ទរកថា, រួបរួមសង្កាត់សុន្ទរកថា ហៅថាសុន្ទរកថា ។

ចំពោះភាសាមនុស្សខ្មែរ មានសង្កាត់សុន្ទរកថា ៨ យ៉ាងគឺ:

១- នាមសព្ទ (nom) ២- គុណនាម (adjectif) ៣- សព្វនាម (pronom) ៤- កិរិយាសព្ទ (verbe) ៥- កិរិយាវិសេសន៍ (adverbe) ៦- និបាតសព្ទ (préposition) ៧- សន្ធានសព្ទ (conjonction) ៨ ឧទានសព្ទ (interjection) ។

## ពាក្យកាព្យ (បទកាកគតិ)

ឯពាក្យគួររួម ហៅប្រយោគព្រម រួមប្រយោគពិត
ហៅថាសេចក្តី រួមសេចក្តីគិត ហៅសង្កាត់ស្និត
សុន្ទរកថា ៗ សង្កាត់រួមច្រើន ប្រមូលបានកើន
ទៅតាមអត្ថា អ្នកប្រាជ្ញឲ្យឈ្មោះ សុន្ទរកថា
អក្សរភាសា ចូរប្រាជ្ញចងចាំ ៗ សង្កាត់សុន្ទរកថា
តាមភាពអត្ថា ប្រាំបីគ្រូផ្ដាំ មួយហៅនាមសព្ទ
ពីរគុណនាមនាំ បីសព្វនាមគាំ បួនកិរិយាសព្ទ
ប្រាំកិរិយាវិសេសន៍ ប្រាំមួយគួរត្រិះ និបាតប្រារព្ធ
ប្រាំពីសន្ធាន ប្រាំបីគួរគាប់ ឧទានសព្ទកប់
ចរនេញឲ្យចាំ ៗ

## ពាក្យសួរ

អ្វីដែលហៅថាប្រយោគ? ការរួបរួមប្រយោគហៅថាអ្វី? ការរួបរួមសេចក្តីបានឈ្មោះថាអ្វី? ការរួបរួមសង្កាត់សុន្ទរកថាអ្នក

ប្រាជ្ញលោកឲ្យឈ្មោះថាអ្វី?

សង្កាត់សុន្ទរកថា មានប៉ុន្មានយ៉ាង អ្វីខ្លះ

## នាមសព្ទ (nom)

អ្វីដែលហៅថា នាមសព្ទ? នាមសព្ទ គឺ សព្ទសំដែងនូវឈ្មោះ មនុស្ស, សត្វ, ទ្រព្យរបស់និងអ្វីៗ ទាំងពួង ។ បើកាលណា គេថា: មន្ត្រី គេហៅឈ្មោះមនុស្ស, សេះ គេហៅឈ្មោះសត្វ, កាំភ្លើង, ឈ្មោះរបស់ ។

នាមសព្ទ មានពីរយ៉ាងគឺ: សាធារណនាមសព្ទ ១, អសាធារណនាមសព្ទ ១ ។

## សាធារណនាមសព្ទ (nom commun)

សាធារណនាមសព្ទ គឺ នាមសព្ទដែលមានទូទៅ ចំពោះ មនុស្ស, សត្វ' របស់ ដូចជា ជាង, ឆ្កែ, រថយន្ត ។

នាមសព្ទ "ជាង" មានទូទៅចំពោះ "ជាងទាំងអស់" ។

នាមសព្ទ "ឆ្កែ" មានទូទៅចំពោះ "ឆ្កែទាំងអស់" ។

នាមសព្ទ "រថយន្ត" មានទូទៅចំពោះ "រថយន្តទាំងអស់" ។

សាធារណនាម អ្នកប្រាជ្ញខ្លះហៅថា សាមញ្ញនាម ព្រោះជា នាមសព្ទដែលមានជាធម្មតា ។

សាធារណនាមសព្ទមាន៥យ៉ាង គឺៈ ពហុសាធារណនាមសព្ទ១, រូបីសាធារណនាមសព្ទ១, អរូបីសាធារណនាមសព្ទ១, សមាស-សាធារណនាមសព្ទ១, នាមនាមសាធារណនាមសព្ទ១ ។

ឬហៅថា ពហុនាម, រូបីនាម, អរូបីនាម, សមាសនាម, នាមនាម ក៏បាន ។

ក) **ពហុនាម** *(collectif)* ពហុនាមបានន័យថា នាមសព្ទ ដែលសំដែងអំពីការរួបរួម, ការប្រមូល មនុស្ស, សត្វ, វត្ថុរបស់ ។

ឧទាហរណ៍ ក្រុម, ហ្វូង, កង, ពួក ។

ពហុនាម មានសភាពទូទៅ បើពហុនាមនេះមានន័យថា មនុស្សទាំងអស់, សត្វទាំងអស់, វត្ថុទាំងអស់ ។

ពហុនាម ដែលមានសភាពបែងចែក ឬ ភាគ, គឺពហុនាម ដែលមាន មនុស្សតែមួយចំណែក, សត្វមួយចំណែក, វត្ថុមួយ

បំណែក ដូចជាៈ បក្ស, ពួក, គណៈ, និកាយ, ហ្វូង, មួយទឹម, មួយកញ្ចប់, មួយឡូ ។ល។

ខ) រូបីនាម (concret) ដែលហៅថា រូបីនាម គឺនាមដែលជាឈ្មោះសត្វ, មនុស្ស, របស់, វត្ថុ ដែលមានរូបកាយទ្រង់ទ្រាយពិតប្រាកដ ឃើញច្បាស់ដោយចក្ខុបសាទ, ពាល់មានសម្ផស្សរឹង, ទន់, គ្រោតគ្រាត ជាដើម ដូចជា មន្ត្រី, គ្រូលី, ដាង, សេះ, ដើមឈើ, ឈើគូស ។ល។

អ្នកប្រាជ្ញខ្លះហៅថា រូបនាម ក៏បាន ។

គ). អរូបីនាម (abstrait) អរូបីនាមបានន័យថា នាមដែលឲ្យឈ្មោះចំពោះគុណសម្បត្តិ, កិច្ចការដែលធ្វើ, លំនាំដែលធ្វើ, មិនមែនជាវត្ថុដែលមានពិតច្បាស់ដោយខ្លួនឯងនេះឡើយ ដូចជាៈក្លាហានភាព, សប្បុរសធម៌ មេត្រីភាព, ប្រាជ្ញា ។

អរូបនាម សំដៅត្រង់នាមដែលមើលមិនឃើញ, ពាល់មិនត្រូវ ។ អរូបនាមគឺ នាមដែលចិត្តបញ្ចេញមានសភាព, លក្ខណៈផ្សេងៗ ។

អ្នកប្រាជ្ញខ្លះហៅថា អរូបនាមក៏បាន ។

ឃ). សមាសនាម (composé) សមាសនាម គឺ នាមដែលមានពាក្យច្រើនជាសមាសភាព ដូចជារាជទ្រព្យ - ព្រះរាជអាណាចក្រ - រាជិកហារិកៈ, អនោមទស្សី - អនោសជ្ឈភាពជាដើម ។

សមាសនាម សំដៅយកសមាស គឺ សព្ទតន្តីកាសាយ៉ាងដូចមគធៈ ឬ សំស្ក្រឹតដែលបំប្រួញបទតាំងពីពីរឡើងទៅឲ្យជាប់គ្នាតែមួយដូចជា

រាជវង្សានុវង្ស = រាជ + វង្ស + អនុវង្ស

សមាហិតចិត្ត - សមា + ហិត + ចិត្ត

ង). នាមនាមៈ នាមនាមគឺពាក្យជា កិរិយាសព្ទ ឬ ជាគុណសព្ទ ថែម “សេចក្ដី” ពីមុខដូចជា “ក្រើន” ជាកិរិយាសព្ទ. “សេចក្ដីក្រើន” ជានាមនាម ។ “ចំរើន” ជាកិរិយាសព្ទ “សេចក្ដីចំរើន” ជានាមនាម ។

“ល្អ” ជាគុណសព្ទ - “សេចក្ដីល្អ” ជានាមនាម;

“អាក្រក់” ជាគុណសព្ទ “សេចក្ដីអាក្រក់” ជានាមនាម ។

បើតាមពិនិត្យសាធារណនាមសព្ទនៅមាននាមមួយទៀត ដែលកើតឡើងពីកិរិយាសព្ទ ដូចដឹង – ដំណឹង, ដើរ=ដំណើរ, ប្រើ=បម្រើ, បាញ់ – ប្រមាញ់, ឈ្នះ ឬ ជំនះ . . . . ល . . បើឲ្យឈ្មោះថា «កិរិយានាម» ក៏បាន ព្រោះជានាមនេះមកពីកិរិយា-សព្ទ ។

មួយយ៉ាងវិញទៀតមានគុណសព្ទបែកចេញទៅជានាម មួយយ៉ាងវិញ ដូចជា "ល្អ" បែកចេញទៅជាលំអ ។ លំអនេះគួរហៅថា "គុណសព្ទនាម" ក៏បាន ព្រោះជានាមកើតឡើងដោយគុណសព្ទ ។

## កាព្យ (ពាក្យ ៧)

នាមសព្ទគឺសព្ទ សំដែងឈ្មោះ
គេហៅចំពោះ មនុស្ស សត្វ ទ្រព្យ
របស់អ្វីៗ តាមប្រាជ្ញ
មន្ត្រីគិតគ្រប់ គឺឈ្មោះមនុស្ស ។
ឆ្កែគឺជាឈ្មោះ របស់សត្វ
កាំភ្លើងគេបាញ់ ហៅត្រង់ឆ្ពោះ

របស់វត្ថុ ប្រាជ្ញឲ្យឈ្មោះ
ឋានៈ ទាប ខ្ពស់ ក្នុងលោកា ។
នាមសព្ទបែកប្រាំ តាមពិនិត្យ
ពហុនាមគិត មានន័យថា
រួបរួមប្រមូល តាមអក្ខរា
ដូចក្រុមមនុស្សា ហ្វូងសត្វគោ ។
ពហុនាម មាន សភាពទូទៅ
តាមប្រាជ្ញប្រដៅ ភាគពេញពោរ
បក្ស, ពួក, គណៈ ហ្វូង មានតាមផ្លូវ
ចូរថាគាប់គួរ រៀនឲ្យស្ទាត់ ។
ឯរូបីនាម នាមមនុស្សសត្វ
មានសណ្ឋានទ្រង់ទ្រាយ បណ្ឌិតចាត់
ឃើញច្បាស់ចក្ខុ ពាល់កាប់កាត់
រឹងទន់ទៀងទាត់ មន្ត្រីគូលី ។
អរូបីនាម មានន័យថា

តាមបទអក្ខរា　　គុណវឿរ

ចរិយាលំនាំ　　កិច្ចពេញទី

បញ្ចេញសោភី　　ល្អអាក្រក់ ។

មើលមិនឃើញច្បាស់　　ពាល់មិនត្រូវ

ក្លាហានជាផ្លូវ　　ពាលខ្លៅល្អក់

សប្បុរសមេត្រី　　វាយោបក់

ដូចទឹកស្រោចស្រក់　　ទន្ទេញជាប់ ។

សមាសនាម　　នាមមានព្យាង្គ

ជាច្រើនរូបភាគ　　នាមនាមគាប់

ពាក្យកិរិយាសព្ទ　　ព្រមគុណសព្ទ

សេចក្តីប្រាវឌ្ឍ　　តាមលក្ខណា ។

កិរិយានាម　　គឺនាមពិត

កើតតាមគូរគិត　　ពីកិរិយា .

គុណនាមសព្ទនេះ　　ពេញរូបា

នាមកើតពីណា　　កុំនឿងឆ្ងល់ ។

ពាក្យសួរ.– អ្វីដែលហៅថានាមសព្ទ? នាមសព្ទមានប៉ុន្មានយ៉ាង?

សាធារណនាមសព្ទ បានន័យថាយ៉ាងណា? ចែកចេញជាប៉ុន្មាន? អ្វីខ្លះ? ចូរអធិប្បាយ ៖

## វិធីហាត់

១– កូនសិស្សរើរកសាធារណនាមសព្ទប្រាំ ដូចតទៅ :

គំរូករណីយកិច្ច : ធាតុ, ដី, ទឹក, ភ្លើង, ខ្យល់, អាកាស

បក្សី : សត្វចតុបាទ, លោហធាតុ, ត្រី, បន្លែ, ដើមឈើ, យានជំនិះ, ខែដែលមាន ៣០ថ្ងៃ, ខែដែលមាន៣១ថ្ងៃ, ល្បែង, ជាតិ, ប្រទេស, បុប្ផា, ប្រដាប់ធ្វើការ, ប្រដាប់សរសេរ, កីឡា ។ ឧបករណ៍វាស់ភ្លើង, គេហដ្ឋាន, មនុស្ស ។

២– ត្រូវដាក់ស្រះត្រង់កន្លែងដែលចុច ដើម្បីឲ្យទៅជាសាធារណៈនាម :

ស.ប, ស្រ.វ, ប.យ, ច.ន, ឃ្ម.ង, ប្រ.សាទ,

.កវ, ប៉ាក., .ផ្លូវ, .ជ, សរ.ស, .ចរ, .បរ, ប្រជ.ប់,

ម.ន់, ទ., .សះ, .ទ្វក, .ជក ។

៣ – ត្រូវដាក់ព្យញ្ជនៈពីមុខត្រង់កន្លែងចុច ដើម្បីឲ្យទៅ

ជាសាធារណនាម:

.ម, .ប, .មឈើ, .វកៅ, .ងប៉ាកា, .នសោរ,

.តូ, .ល់, ទ.ទូ, ស.ទ្រ, ស្លឹង, .នក្មេង, .រក, .ញ្ញា, .ប្អា,

៤ – ត្រូវធ្វើប្រយោគមួយយ៉ាងខ្លីចំពោះសាធារណនាម

ខាងក្រោម:

ប្រជាជាតិ, មាតុភូមិ, ព្រះអាទិត្យ, សត្វលោក, គោ, ក្របី,

សេះ, ដំរី សមុទ្រ, ទ្វីប, គ្រកូល, ការងារ, ខ្សែដៃ, ចំពៀន

កង់, មួក, ស្បែកជើង, ខោ, អាវ, ទន្លេ, ស្ទឹង, បឹង, អណ្ដូង,

ផ្លូវ, ផ្ទះ, រថយន្ត, មេឃ, ផ្កាយ, ព្រះចន្ទ, ប្រកព, សប្បុរស,

ដាវ, លំពែង, មេសំពៅ ។

៥– ត្រូវរកនៅក្នុងពាក្យខាងក្រោម តើពាក្យណាជា ពហុ-

នាម, រូបីនាម, អរូបីនាម, សមាសនាម, នាមនាម ?

ហ្វូងគោ, សត្វចាប, សត្វចៀម, សត្វមាន់, ជ្រូក, ក្តាន់, សេចក្តីក្លាហាន, សប្បុរិសធម៌, ឧបេក្ខាចិត្ត, អភិធម្ម, សុត្តន-បិដក, ទុច្ចរិត, សុចរិត, មេត្រីភាព, សេចក្តីលោភ, អព្យាក្រិត្យ, ប្រក្រតី, ក្លាហាន, ប្រាជ្ញា, ស្មារតី, កុហក, សេចក្តីខ្លាច, ក្រុម-ឯកច្ឆាន, ពួកកូនសិស្ស, គណបក្សតម្កើងប្រជាជាតិ, កុក, ត្រី, ស្ទឹង, បឹង, គណៈបក្សឯកពក្យ ។

៦– ត្រូវរិះរកនូវអត្ថបទខាងក្រោមនេះនូវពហុនាម, រូបីនាម, អរូបីនាម, សមាសនាម, នាមនាម, កិរិយានាម, គុណនាម ។

## វិជ្ជាកំចាត់ល្ងង់ខ្លៅ

វិជ្ជាកំចាត់ល្ងង់ខ្លៅមាន ៧ យ៉ាង គឺ:

១– ឲ្យឧស្សាហ៍សាកសួររបស់ដែលខ្លួនមិនដឹងមិនចូលចិត្ត ។

២– ឲ្យឧស្សាហ៍សំអាតរូបកាយ, សំលៀកបំពាក់ គ្រឿងប្រើប្រាស់ និងទីលំនៅឲ្យស្អាតកុំឲ្យប្រឡាក់អាក្រក់ ។

៣– ឲ្យធ្វើរបស់ទាំងប្រាំ គឺ សេចក្តីជឿ, សេចក្តីព្យាយាម,

សេចក្ដីព្យក, សេចក្ដីតាំងចិត្ត, សេចក្ដីត្រិះរិះឲ្យកើតមានស្មើ ៗ គ្នា កុំឲ្យតិចច្រើនជាងគ្នា ។

៤— កុំសេពគប់មនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ ព្រោះនឹងធ្វើខ្លួនអ្នកសេពគប់ឲ្យល្ងង់ខ្លៅទៅតាមគេផង ។

៥— ឲ្យសេពគប់តែនឹងមនុស្សមានប្រាជ្ញាឈ្លាសវៃ ព្រោះនឹងធ្វើខ្លួនអ្នកសេពគប់ឲ្យមានប្រាជ្ញាឈ្លាសវៃទៅតាមគេផង ។

៦— ឲ្យយកចិត្តទុកដាក់ក្នុងការស្រាវជ្រាវរកហេតុផលផ្សេង ៗ ដែលខ្លួនបានជួបប្រទះ គឺការជួបប្រទះរបស់អ្វីដែលខ្លួនមិនដឹងរឿង ឬមិនដឹងដើមចុងរបស់នោះ ត្រូវពិចារណាឲ្យកាន់តែបានដឹង កុំធ្វើព្រងើយកន្ដើយ ។

៧ — ឲ្យយកចិត្តទុកដាក់ក្នុងផ្លូវដែលធ្វើឲ្យឈ្លាសវៃជានិច្ច ទោះបីធ្វើអ្វីក៏ដោយត្រូវតែចាំឲ្យប៉ិនប្រសប់ក្នុងរបស់នោះ ដូចជាការបង្កាត់ភ្លើងកល់តែពេល ដែលបង្កាត់ភ្លើងត្រូវតែគិតពិចារណាថាធ្វើម្ដេចទើបភ្លើងនឹងឆេះឆាប់ ចាំគិតឲ្យទាល់តែចេះដឹងយល់ច្បាស់ក្នុងកិច្ចបង្កាត់ភ្លើងនេះដូច្នេះជាដើម ។

កាលបើធ្វើតាមគោលទាំង ៧ ប្រការនេះបានហើយ នឹងអាចកំចាត់សេចក្ដីល្ងង់ខ្លៅចេញបានជាប្រាកដ ត្រឡប់ទៅជាអ្នកមានប្រាជ្ញាឈ្លាសវៃប៉ិនប្រសប់មិនខាន ។

ឃុនបណ្ណានុរក្ស ប៉ិប៉ី

(វិជ្ជារក្សាចិត្តក្នុងបច្ចុប្បន្នសុមង្គលវិលាសិនី)

## ២ - អសាធារណនាមសព្ទ

អសាធារណនាមសព្ទគឺ នាមនាម ដែលមិនទូទៅទៀត ឬនាមពិសេសដែលជាកម្មសិទ្ធិចំពោះបុគ្គលម្នាក់ ៗ, សត្វមួយ ៗ ឬរបស់មួយ ៗ ដូចជា នាយសួន, នាងតាក, ទូទូ (ឈ្មោះឆ្កែ), ប្រទេសកម្ពុជា ។

នាម "សួន" នេះមិនមានទូទៅចំពោះមនុស្សទាំងអស់ ។

នាម "ទូទូ" មិនមានទូទៅចំពោះឆ្កែទាំងអស់ ។

នាម "កម្ពុជា" មិនមានទូទៅចំពោះប្រទេសទាំងអស់ ។

អសាធារណនាម, មានបណ្ឌិតខ្លះហៅថា វិសាមញ្ញនាម ព្រោះជានាមមិនមានជាធម្មតា ។

## ពាក្យកាព្យ (ពាក្យ ៧)

អសាធារណ នាមសព្ទនេះ
គួរសិស្សចាំចេះ បានន័យថា
នាមនាមមិនទូ- ទៅទិសា
នាមបុគ្គលណា ម្នាក់ៗឯង ។
នាមសត្វតែ បានតែម្នាក់
ទីងហៅជាងជាក់ តាមពោលថ្លែង
ឲ្យគ្រប់ទាំងអស់ បណ្ឌិតបែង
មិនបានញែកបែង តាមធម្មតា ។
បណ្ឌិតខ្លះឈ្មោះវិ- សាមញ្ញនាម
បែបលំនាំតាម គិតរចនា
ព្រោះជានាមប្លែក បានឯកា
មិនមែនច្រើនគ្នា គួរយល់សព្វ ។

ពាក្យសួរ -- អ្វីដែលហៅថា អសាធារណនាម ?

ឧទាហរណ៍ -

បណ្ឌិតខ្លះហៅថា យ៉ាងណា ? ព្រោះហេតុអ្វី? ។

## វិធីហាត់

១ - ឲ្យរកអសាធារណនាមប្រាំពីរចំពោះប្រទេស, សត្វ, មនុស្ស, អ្នកនិពន្ធ, អ្នកកវីបណ្ឌិត, សង្គ្រាម, រដ្ឋមន្ត្រី, នាយករដ្ឋមន្ត្រី, ទីក្រុង, ទន្លេ, ស្ទឹង, សមុទ្រ, ប្រាសាទ-បុរាណ, ព្រះមហាក្សត្រិយប្រទេសកម្ពុជា, ព្រះពុទ្ធ, ព្រះអគ្គសាវក

២ - ឲ្យរកអសាធារណនាមចំពោះអត្ថបទខាងក្រោម :

## ព្រះពុទ្ធតិស្ស:

ព្រះមាតានាមព្រះនាងបទុមា ព្រះបិតាជាក្សត្រព្រះនាមជន-សន្ធ អគ្គមហេសីនាមព្រះនាងសុភទ្ទា ព្រះរាជបុត្រព្រះនាមអានន្ទ ក្នុងនគរឈ្មោះខេមកៈ ព្រះជន្មាយុ ៧ ពាន់ឆ្នាំ ទើបចេញបព្វជ្ជា ដោយសេះ ធ្វើទុក្ករកិរិយាកន្លះខែ ដើមផ្ចង់ជាពោធិព្រឹក្សអគ្គសាវក

២ រូបគឺៈ ព្រហ្មទេវៈ១, ខេមយៈ១, ខេបង្កក ១ រូប ឈ្មោះ សមគៈ

អគ្គសាវិកា ២ រូបគឺ ផុស្សា, សុទន្ដា ១ ។

ឃុនសិរីមេធី ស្រ៊-អ៊ូ

(ពុទ្ធប្រវត្តិសង្ខេប)

៣– ចូរបញ្ជាក់តើបុគ្គលបែបណា, វត្ថុ, អសាធារណ-នាម ខាងក្រោម :

ព្រះបាទជយាវរ្ម័នទី ៧, កំពង់ឆ្នាំង, ស្ទឹងសែន, ភ្នំខ្មោច, កោះត្រល់, ឈូងសមុទ្រសៀម, លោកឧកញ្ញាសុតន្តប្រីជាឥន្ទ, ព្រះបាទសម្តេចព្រះនរោត្តម, ពោធិ៍សាត់, លោកសីទ្ធហាម៉ុក, ព្រះបាទសូរិយាវរ្ម័នទី ២, ព្រះបាទសូរិយាវង្ស, ស្តេចដំបងក្រញូង, ស្ទឹងបាត់ដំបង, វិទ្យាល័យស៊ីសុវត្ថិ, ស្ពានមុនីវង្ស, វិថីតាត្រសក់ផ្អែម, ភូមិបឹងកិន, ក្រុងកំពត, ស្រុកពោចិនតុង, រលព្រា, ភ្នំដងរែក, ស្ទឹងជីនិត, ប្រាសាទអង្គរ, ទន្លេសាប, ព្រះរាជធានី-ភ្នំពេញ, ព្រៃក្រឡាញ់, កោះកុង, ភ្នំក្បាលដំរី ។

# គុណសព្ទ (adjectif)

១– ន័យយ៉ាងដូចម្តេចដែលហៅថាគុណសព្ទ? គុណសព្ទ គឺសំដីដែលប្រាប់ដំណើរនាមសព្ទឲ្យឃើញលក្ខណៈផ្សេងៗគ្នា ដូចជា មនុស្សខ្មៅ, ផ្ទះធំ, ផ្លូវត្រង់ ។ ពាក្យថា ខ្មៅ, ធំ, ត្រង់, ដែលបញ្ជាក់នូវលំនាំរបស់មនុស្ស, ផ្ទះ, ផ្លូវ ហៅថាគុណសព្ទ ។ គុណសព្ទជាពាក្យមួយដែលបន្ថែមទៅលើនាមសព្ទ ដើម្បីបង្ហាញនូវគុណសម្បត្តិ ឬបញ្ជាក់ឲ្យច្បាស់លាស់នូវនាមសព្ទនោះ ។

## ២ សមាសភាពនៃគុណសព្ទ

គុណសព្ទមានសមាសភាពដូចខាងក្រោម:

ក) គុណនាមគុណសព្ទ *(adjectif qualficatif)*

ខ) សាមិសម្ពន្ធគុណសព្ទ *(adjectif possessif)*

គ) និទស្សនៈគុណសព្ទ *(adjectif démonstratif)*

ឃ) បុច្ឆាគុណសព្ទ *(adjectif interrogatif)*

ង) អនិយមគុណសព្ទ *(adjectif indéfini)*

ច) សង្ខ្យាគុណសព្ទ *(adjectif numéral)*

# គុណនាម គុណសព្ទ
## (adjectif qualificatif)

១ – គុណនាមគឺពាក្យមួយដែលបន្ថែមទៅលើនាមសព្ទ ដើម្បីនឹងសំគាល់នូវគុណវិសេស ឬ គុណសម្បត្តិនៃនាមសព្ទនោះ ។

ឧទាហរណ៍ = មនុស្សទាប, ស្រីល្អ, កូនក្មេងតូច, ផ្លែធំ: ដើមឈើខ្ពស់ ។

ពាក្យទាប, ល្អ, តូច, ធំ, ខ្ពស់ ដែលបន្ថែមឲ្យដឹងគុណ-សម្បត្តិរបស់មនុស្ស, ស្រី, កូនក្មេង, ផ្លែ, ដើមឈើហៅថា គុណនាម ។

គេអាចសំគាល់បានថា ពាក្យជាគុណសព្ទ គឺពាក្យដែលគេអាចភ្ជាប់នាមសព្ទបាន ដូចជាពាក្យថា: ស្អាត, អាក្រក់, គោង, វៀច, ត្រង់, ជាគុណសព្ទព្រោះគេអាចថាបាន ស្រីស្អាត, មនុស្ស អាក្រក់, ផ្លូវគោង, ឈើវៀច, កូនសិស្សត្រង់បាន ។

២ – គុណសម្បត្តិមានពីរយ៉ាងគឺ: គុណសព្ទខាងចិត្តនិយម ឬគុណសម្បត្តិខាងសីលធម៌ ១, គុណសម្បត្តិខាងរូបនិយម ឬគុណ

សម្បត្តិខាងសម្ភារៈ ៗ ។

គុណសម្បត្តិខាងចិត្តនិយម គឺគុណសម្បត្តិចំពោះមនោធម៌, ប្រាជ្ញានឹងចិត្ត គឺគុណសម្បត្តិដែលស្ថិតនៅក្រៅអាយតនៈទាំងប្រាំ គឺជានាមធម៌សុទ្ធៗ ។

ដូចជាថា: ចារកមានប្រាជ្ញា, ទាហានក្លាហាន, មនុស្សល្អ, នារីស្លូត, នាហ្មឺនត្រង់, ក្មេងកុហក ។

មានប្រាជ្ញា; ក្លាហាន, ស្លូត, ត្រង់, កុហក់ សុទ្ធតែគុណសម្បត្តិខាងផ្លូវចិត្ត, ខាងសីលធម៌ ។

គុណសម្បត្តិខាងរូបនិយមគឺ គុណសម្បត្តិដែលមានសមភាគ ឬបច្ច័យទាក់ទងនឹងរូបដោយរបស់ទាំងនេះនៅក្នុងអាយតនៈប្រាំ គឺរូបធម៌, តែងមានបច្ច័យទាក់ទងនឹងអារម្មណ៍ទាំងប្រាំ, អ្នកប្រាជ្ញខ្លះថា ជាគុណសម្បត្តិដោយសម្ភារៈដូចជា:

ស្រីស្អាត, ប្រុសធំ, ផ្លូវវែង, ក្មេងខ្ចី, មនុស្សធាត់, កូនសិស្សតូច, ទាហានខ្មៅ ។

ស្អាត, ធំ, វែង, ខ្ចី, ធាត់, តូច, ខ្មៅ នេះជាសម្បត្តិខាងរូបនិយមៗ

# ៣- សមាសនាម

គុណនាមមានបីគឺ:

ក) បកតិគុណនាម

ខ) វិសេសគុណនាម

គ) អតិវិសេសគុណនាម

## (ក បកតិគុណនាម

បកតិគុណនាម គឺគុណនាមសំដែងទៅតាមប្រក្រតី ដូចពាក្យថា ក្តៅ, សក់ខ្វី, ក្រដាស់ក្រាស់, ដីមូល, ផ្ទះធំ ជាដើម ។

## ខ) វិសេសគុណនាម

វិសេសគុណនាម ឬអតិវិសេសគុណនាម ជាព្យញ្ជនៈខ្វះដែលគុណនាមយកមកប្រើដោយបញ្ចូលនូវគំនិត ទីនៃសេចក្តីប្រើជាគ្រឿងប្រៀបធៀប ។ មនុស្សនេះធំ, បំណែកមនុស្សខាងនោះខ្ពស់ជាងគេ, កូនទាវចាំងអស់, នារីនេះមានសាច់សផង ។

ធំជាគុណនាម, ខ្ពស់ជាងគេជាវិសេសគុណនាម, សាច់

សផង៍ ជាអតិវិសេសគុណនាម ។

វិសេសគុណនាម គុណនាមដែលជាគុល្យាធិករណៈជាមូលដ្ឋាន ហៅថា វិសេសគុណនាម ។ គុល្យាធិករណៈមាន ៣ យ៉ាងគឺៈ

ក) គុល្យាធិករណៈ ជាហ៊ីនភាពដែលមាន អាយតនិបាត តាបជាង, តិចជាង, ដូចជាមនុស្សនេះសប្បាយតិចជាងខ្ញុំ ។

ខ) គុល្យាធិករណៈ ជាសភាពដែលមាននិបាតសព្ទដូចគ្នា, ស្មើគ្នា, ដូចជាៈ ផ្ទះនេះធំដូចគ្នានឹងផ្ទះខ្ញុំ, ក្មេងនេះខ្ពស់ស្មើគ្នា នឹងក្មេងនោះ ។

គ) គុល្យាធិករណៈ ជាវិសេសដែលមាននិបាតសព្ទច្រើន ជាង, វិសេសជាង, ប្រសើជាង, ឧទាហរណ៍ៈ មនុស្សនេះ សប្បាយច្រើនជាងមនុស្សខ្ញុំ ។

## (គ អតិវិសេសគុណនាម

អតិវិសេសគុណនាម គុណនាមដែលមានជាអតិវិសេស លុះត្រាតែគុណនាមនោះ បានឲ្យន័យនូវគុណសម្បត្តិវិសេសវិសាល ជាងគេហៅថា អតិវិសេសគុណនាម ឧទាហរណ៍ៈ ។

ប្រាសាទអង្គរ ជាប្រាសាទបុរាណវិសេសជាងប្រាសាទទាំងអស់ក្នុងកម្ពុជរដ្ឋ ។

នារីនេះមានសាច់សស្រស់ជាងគេ ។

នារីនេះល្អឆើតឆាប់ជាងនារីទាំងអស់ ។

បុរសនេះមានស្បែកជើងខ្មៅយង់ ។

## គុណសព្ទ (កាព្យពាក្យ៩)

គុណសព្ទគឺ សំដីកែ ប្រាប់ដំណើរ
នាមសព្ទឃើញ ការប្រសើរ លក្ខណៈ
ផ្សេងៗគ្នា ឬបន្ថែម លើនាមៈ
គុណសម្បត្តិ កបអក្ខរៈ បញ្ជាក់ច្បាស់ ។
មួយគុណនាម គឺពាក្យមួយ បន្ថែមនាម
ដើម្បីសំ- គាល់វង្សឈាម គុណស្រឡះ
ល្អអាក្រក់ ខ្មៅឬស ប្រាជ្ញវៃឆ្លាស់
ចូរចំរៀន ប្រកបណាស់ ឲ្យអស់ឆ្ងល់ ។

| | | |
|---|---|---|
| ពីរសាម- | សម្ពន្ធៈ | គុណសព្ទពិត |
| បីនិងសប្ត- | នះគួរគិត | យល់សែនសល់ |
| បួនបុប្ផា | គុណសព្ទបារ | តាមកិច្ចកល |
| ប្រាំអនិ- | យមកបផល | ប៉ុនសន្ធិ្យា ។ |
| គុណនាមញែក | មកតិ | គុណនាមពោល |
| វិសេសគុណ- | នាមតាមគោល | បណ្ឌិត្យា |
| អតិវិ- | សេសគុណនាម | បូរកុមារ |
| រៀនឲ្យចាំ | ស្ទាត់អត្ថព | តាមការគួរ ។ |

<u>ពាក្យសួរ</u> – យ៉ាងដូចម្ដេចដែលហៅថា គុណសព្ទ? ឧទាហរណ៍!

គុណសព្ទ មានសមាសភាពប៉ុន្មាន, អ្វីខ្លះ?

យ៉ាងដូចម្ដេចដែលហៅថា គុណនាម? គេសំគាល់បានយ៉ាងណាខ្លះ?

គុណសម្បត្តិមានប៉ុន្មានយ៉ាង? អ្វីខ្លះ? ឧទាហរណ៍!

អ្វីដែលហៅថា បកតិគុណនាម? ចូរពណ៌នាប្រៀបធៀបមក មើល!

អ្វីដែលហៅថា វិសេសគុណនាម? ឧទាហរណ៍ -

អតិវិសេសគុណនាម បានន័យថាយ៉ាងណា? ឧទាហរណ៍ ។·

## វិធីហាត់សរសេរ

១– ត្រូវរកនាមដាក់ពីមុខគុណនាមតាមសមគួរ គឺ:

ខ្មៅ, តូច, ទាប, អាក្រក់, ស, ស្អាត, ស្គម, ស្ងួត, កាច, ត្រង់, វែង, ធំ, ល្អ, ខ្ចី, ស្ដុក, ក្រាស់ ។

២– ត្រូវរកគុណនាមដាក់ត្រង់បន្ទាត់គួរ

ផ្ទះខ្ញុំ___, ទន្លេមេគង្គ___, ក្មេងនេះ___, សេះ___, ក្ដំផនវែក___, ពល___, ព្រៃ___, ផ្លូវ___, ស្រី___, ដើមឈើ___, មាន់___, តុ___, ថ្ម___, ក្លើង___, ផ្សែង___, ចាន___, ចោរ___, កំពង់___, ប្រាំងស្ងឹង___, គោ___, ចិន___ ។

៣ – ត្រូវរកគុណនាមដាក់ភ្ជាប់នឹងនាមៈ

ពិត, កាច, គ្រាស់, ស្ងួត, ស្រួច, សប្បុរស, ពាល, លំទ្ធត, ខ្មៅ, ស្អាត, ល្អ, លឿន, គ្រអូប, ល្វីង, ទន់, ក្រហម, ខាប, ពិរោះ, ក្លឹ, ថ្លា, ស ៗ

ស្បង់លោកសង្ឃ, សំដី, បន្ទប់, មនុស្ស, ក្មេង, សំ-ឡេង, ទឹក, នារី, បុប្ផា, ដៃស្រី, កុឡាប, សាច់ត្រី, ចិត្ត, បុរស, ក្អែក, ផ្ទះ, ព្រៃ, ទារក, បន្លា, បណ្តូលពេជ្រ, ត្រកូល ៗ

៤ – ត្រូវរកក្នុងអត្ថបទនេះនូវគុណនាម ដែលមានចាំន-ប៉ុន្មាន ៗ

## ព្រះបាទអសោកមហារាជ

ព្រះបាទអសោកមហារាជទ្រង់ទំនុកបម្រុងជប់លៀងព្រះអនុជនឹងព្រះជេដ្ឋាដោយល្អ ឥតមានការប្រទុស្សរាយគ្នាឡើយ ៗ ព្រះបាទអសោកមហារាជនេះ ទ្រង់ជាអ្នកមានលក្ខណៈរឹងប៉ឹងដាច់ស្រេចម៉ឺងម៉ាត់ តែមិនមែនជាក្សត្រកាចសាហាវដូចជាមានសំដែង

ទុកក្នុងគម្ពីរខ្លះនោះទេ ។ ពិតមែនតែព្រះអសោកមហារាជទ្រង់ធ្វើសឹកសង្គ្រាមច្រើនក៏ជាធម្មតា អស់មហាក្សត្រគ្រប់ៗអង្គដែលត្រូវការស្វែងរកអំណាចផ្សាយតេជានុភាព ពង្រីកអាណាខេត្តរបស់ព្រះអង្គ ។ ឯព្រះបាទអសោកមហារាជនេះ ទ្រង់ប្រកបដោយឫទ្ធិអំណាចយ៉ាងធំសំបើម ១ ក្នុងពង្សាវតាររបស់លោក ។ រាជអាណាខេត្តរបស់ព្រះបាទអសោកមហារាជនោះ ធំទូលាយសំបើមណាស់, ជិតគ្រប់អស់ដែនឥណ្ឌាទាំងមូល ។

## ហ្វឹកពន្លមត្រី ពាក្យ_ថែម

(ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា)

៤— ត្រូវផ្គាស់បន្ទាត់ខ្លួនដាក់គុណសម្បត្តិសីលធម៌, ឬដាក់គុណសម្បត្តិសម្ភារ.. ត្រង់កន្លែងចុច ៗ គឺពង្រ.... ។

មនុស្សស្រីមានសាប់ ... កូនសិស្សរៀនសូត្រព្យាយាម.

ដើមឈើមានសំបក .... ផ្ទះខ្ញុំ... ពានហានត្រូវមានចិត្ត..

ចូលក្នុងសមរភូមិ ។ នារីនេះមានស្បែក ... ស្ទឹងនេះ....

មាន់.... ត្រូវការហើយ .... ស្រែកគ្រប់ ....

អ្នកប្រាជ្ញគ្មានចិត្ត -- ទេ, ទោះ -- កាប់ សម្លាប់ល្អបប្អូន

ទ្រព្យសម្បត្តិ, សំពត់ខ្លះមានពណ៌ . : . . . ខ្លះទៀតមាន

ពណ៌.... ។

# សាមីសម្ពន្ធ គុណសព្ទ

## (adjectif possessif)

១ — ន័យ .— គុណសព្ទដែលបញ្ជាក់អំពីម្ចាស់របស់ ខ្ញុំសូមកំណត់ហៅ, (សូមអភ័យទោសអំពីអ្នកវេយ្យាករណ៍បណ្ឌិតដោយពាក្យនេះមិនទាន់កំណត់) ថា សាមីសម្ពន្ធគុណសព្ទ ។ សាមីប្រែថា ម្ចាស់របស់; សម្ពន្ធប្រែថា ការចងភ្ជាប់គ្នា - ដំណើរទាក់ទងគ្នា ។

សាមីសម្ពន្ធគុណសព្ទ ជាគុណសព្ទសម្រាប់បញ្ជាក់តែបុគ្គលសត្វ, វត្ថុនោះជារបស់អ្នកណា? ។

សាមីសម្ពន្ធគឺ: ខ្ញុំ, ឯង, វា, គាត់, យើង, អ្នក, អ្នកទាំងអស់គ្នា ។

<u>សេចក្ដីពិនិត្យ</u> .— សាមីសម្ពន្ធ គុណសព្ទខាងវេយ្យាករណ៍ខ្មែរមិនមានបុំលិង្គ, ឥត្ថីលិង្គ ឬ ឯកវចនៈ ឬ ពហុវចនៈសោះឡើយ ប្រុសថា ខ្ញុំ, ស្រីថា នាងខ្ញុំ; ប្រុសច្រើន ឬ ស្រីច្រើនថា អ្នកទាំងអស់, ឬ នាងទាំងអស់ ។

## ២ សាមីសម្ពន្ធជាពាក្យកាព្យ (ពាក្យ៧)

| | |
|---|---|
| សាមីសម្ពន្ធ | ជាគុណសព្ទ |
| បញ្ជាក់តាមច្បាប់ | ម្ចាស់របស់ |
| ខ្ញុំ, ឯង, វា, គាត់ | យើងអ្នកស្មោះ |
| បញ្ជាក់តាមឈ្មោះ | បុគ្គលសព្ទ ។ |

៣ – ពាក្យសួរៈ អ្វីដែលហៅថា សាមីសម្ពន្ធ គុណសព្ទ? ចូរអធិប្បាយ, សាមីសម្ពន្ធគុណសព្ទ គឺអ្វីខ្លះ?

## ៤ វិធីហាត់សរសេរ

ក)· ចូរអ្នកផ្លាស់បន្ទាត់គូសដាក់សាមីសម្ពន្ធ គុណសព្ទ –

ចូរអ្នកស្រឡាញ់មិត្តមាតារបស់ ________

វិជ្ជាបានចូលមកដល់ម្ចាស់ ________

ឆ្មាចូលមកលិតបាតដៃម្ចាស់ ________

ចូរអ្នកប្រព្រឹត្តករណីយកិច្ចរបស់ ________

ឯងត្រូវអានសៀវភៅរបស់ ________

អាពុកខ្ញុំគាត់ស្រឡាញ់កូន ______

មនុស្សទាំងអស់ ជាជាងរចនានូវជោគវាសនារបស់ ______

អ្នកឯងកុំទុកចិត្តមិត្តដែលគប់មកយូរហើយរបស់ ______

## ១) ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌៀ ក្នុងរាជ្យព្រះបាទកនិស្កៈ

សាសនាជាប្រស្នាយ៉ាងសំខាន់ ក្នុងការគ្រប់គ្រងស្រុកទេស របស់ក្សត្រឥណ្ឌៀគ្រប់ៗអង្គរៀងមក ជនជាតិឥណ្ឌៀមិនសូវបេះ នឹករលឹកស្រឡាញ់ជាតិកំណើតរបស់ខ្លួនទេ ហើយទាំងមិនយក ចិត្តទុកដាក់នឹងស្រុកទេសរបស់ខ្លួនផង តែមានរបស់មួយដែល ជនជាតិយកចិត្តទុកដាក់ជាយ៉ាងក្រៃលែង តាំងអំពីកំណើតពង្សាវ-តាររហូតមកដល់ឥឡូវនេះ គឺរឿងសាសនា ។ ឯព្រះមហាក្សត្រ ក្នុងពង្សវង្សយូរអេចអំពីដើម ៗ មកនោះ អង្គខ្លះក៏ទំនុកបំរុងសាសនា ព្រាហ្មណ៍ដំកល់ដំកើងព្រះរបស់ឥណ្ឌូ តែមកដល់សម័យព្រះបាទ កនិស្កៈ ទ្រង់ទំនុកបម្រុងព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ ដល់ទៅ

ប្រាក់សម្រាប់ចាយវាយក្នុងរាជអាណាចក្ររបស់ព្រះអង្គ មានទាំងព្រះរូបរបស់ព្រះពុទ្ធជាម្ចាស់ផង ហើយទ្រង់បានកសាងវិហារ សាលាទីនព្រះស្តូបឡើងថ្មី ៗ រាប់មិនអស់ ។

## ហង្គិតពន្ធមន្ត្រី ញុក-បើម

ចូរអ្នកដកស្រង់នូវសាមីសម្ពន្ធគុណសព្ទ ដែលមានក្នុងអត្ថបទខាងលើ ។

ក)- ចូរអ្នកយកសាមីសម្ពន្ធគុណសព្ទខាងក្រោមនេះ ទៅធ្វើជាប្រយោគមួយ ៗ ដូចជា: កូនរបស់ខ្ញុំឧស្សាហ៍សូត្ររៀន ។

ខ្ញុំ, គាត់, ខ្លួន, អ្នក, អ្នកទាំងអស់, នាងទាំងអស់, លោក, លោកស្រី, អ្នកស្រី, អ្នកគ្រូ, វា, ឯង, ព្រះអង្គ, យើង ។

# និទស្សនៈគុណសព្ទ

## (adjectif démonstratif)

១ – ន័យ ៖ ដែលហៅថា និទស្សនគុណសព្ទ គឺគុណសព្ទដែលសម្រាប់បង្ហាញ បុគ្គល, សត្វ ឬវត្ថុដែលគេពោល, និយាយ, ពណ៌នា ។

និទស្សនៈគុណសព្ទគឺ: នេះ, នោះ ដូចជាថា: ត្រនេះ, ផ្ទះនោះ ។

២– ពាក្យកាព្យ (ពាក្យ៧)

| | |
|---|---|
| និទស្សនៈ | គុណសព្ទពិត |
| អ្នកប្រាជ្ញគួរគិត | តាមអក្ខរា |
| សម្រាប់បង្ហាញ | មនុស្សា |
| បុគ្គលសត្វណា | វត្ថុទៀត ។ |

៣ – ពាក្យសួរ- អ្វីដែលហៅថានិទស្សនៈគុណសព្ទ?

ឧទាហរណ៍ ...

៤– វិធីហាត់សរសេរ

ក) ចូរផ្ចាស់បន្ទាត់គូសដាក់និទស្សនៈគុណសព្ទ

សៀវភៅ ——, ផ្លូវ ——, មនុស្ស ——, ឆ្កែ ——, ដើមឈើ ——, កូនសិស្ស ——, កាំបិត ——, ស្រី ——, ប្រុស ——, លោកសង្ឃ ——, ព្រៃ ——, ឆ្មាំ ——, ស្ពឹង ——, ទន្លេ ——, ផ្កាយ ——, ព្រះចន្ទ ——, ព្រះអាទិត្យ —— ។

១) អត្ថបទ ផ្ទះរបស់ខ្ញុំ

ផ្ទះខ្ញុំស្ថិតនៅវិថីប៉ាស្ទ័រ, វិថីនេះវែងជាងគេ ។ នៅមុខផ្ទះខ្ញុំ មានផ្លូវតូចមួយដែលចុះពីវិថីប៉ាស្ទ័រតម្រង់ទៅទិសខាងលិច ។ នៅចុងផ្លូវតូចខាងនោះ មានគេហដ្ឋានមួយដែលជារបស់លោកស័កប៊ីអ៊ុំ មេទ័ពល្បីល្បាញក្នុងសម័យ ។

## បុច្ឆាគុណសព្ទ

**(adjectif interrogatit)**

១ – អ្វី – បុច្ឆាគុណសព្ទ គឺជា គុណសព្ទសម្រាប់សួរ ។

ដូចជា:

តើ · អ្នកមកតើមានការអ្វី ?

ធម៌អរិយសច្ច តើ គឺអ្វីខ្លះ?

តើអ្នកអាយុប៉ុន្មាន?

## ២ - ពាក្យកាព្យ (ពាក្យ៧)

បុប្ផាគុណសត្វ សម្រាប់សួរ
ពាក្យ តើគាប់គួរ មានតែមួយ
ពាក្យនេះប្រើបាន ជាជំនួយ
នាមសត្វជាមួយ សត្វនាមហើយ ។

## ៣ - ពាក្យសួរ

អ្វីដែលហៅថា បុប្ផាគុណសត្វ? អ្វីខ្លះ?

## ៤ - វិធីហាត់សរសេរ

ចូរអ្នកដាក់បុប្ផាគុណសត្វ ត្រង់បន្ទាត់ដែលគួរ ។

__________ ផ្ទះអ្នកស្ថិតនៅវិថីណា ?

__________ មនុស្សនេះ នាមអ្វី?

__________ វិថីនេះ ឈ្មោះអ្វី?

__________ នារីនេះជាកូនអ្នកណា ?

__________ បុរសនេះ មកពីណា ?

__________ សត្វនេះឈ្មោះអ្វី ?

## អនិយមគុណសព្ទ

**(adjectif indéfini)**

១- ន័យ- អ្វីដែលហៅអនិយមគុណសព្ទ, អនិយមគុណសព្ទ គឺជាគុណសព្ទដែលបង្ហាញ ឬបញ្ជាក់នាមដោយមិនច្បាស់លាស់, មិនបញ្ចេញឲ្យប្រាកដ ។

ដូចជា: ទាំងអស់, ទាំងនេះ, ទាំងនោះ, នីមួយ, ច្រើន ។

មនុស្សទាំងអស់ ធ្វើការប្រយោជន៍ជាតិ ។

មនុស្សទាំងនេះ ព្យាយាមគោរពគ្រប់គ្នា ។

មនុស្សទាំងនោះ មិនសូវមានចំណេះ ។

មនុស្សខ្លះល្អ មនុស្សខ្លះបេះ ។

មនុស្សនីមួយ ៗ ត្រូវតែព្យាយាមរៀនសូត្រ ។

មនុស្សច្រើនមិនសូវនឹកដល់អនាគតប្រទេសជាតិ ។

## ២- ពាក្យកាព្យ (បទកាកគតិ)

អនិយមពិត គុណសព្ទគួរគិត បញ្ជាក់នាមសព្ទ
មិនបានច្បាស់លាស់ មិនប្រាកដប្រាប់ ពេល ៗ មិនគាប់
មិនយល់ន័យឡើយ ។

## ៣- ពាក្យសួរ .— អ្វីដែលហៅថាអនិយមគុណសព្ទ?

ឧទាហរណ៍--

## ៤- វិធីហាត់សរសេរ

ចូរដាក់អនិយមគុណសព្ទជំនួស ត្រង់គំនូសដែលគូស

ពាក្យអំនួតបំផ្លាញនូវគុណសម្បត្តិ—— ។

មាន —— ជាអាហារមនុស្សលោក ។

ត្រូវទុកកន្លែងមួយសម្រាប់ដាក់របស់ —— ។

របស់ —— ត្រូវតែមានកន្លែងសម្រាប់ទុក ។

បទបញ្ញត្តិច្បាប់ គឺជាវិធានមួយ ស្ថាបនាដោយជន:ប្រជាជាតិ ហើយ

ត្រូវតែពលរដ្ឋ —— ប្រតិបត្តិតាម ។

ពួកគាកសាស្ត្រជាផ្កាយ —— សុទ្ធតែមានសត្វនៅ ។

មនុស្ស —— ធ្វើការប្រយោជន៍ខ្លួន ៗ

មនុស្ស —— ត្រូវប្រតិបត្តិតាមច្បាប់ ៗ

ស្ត្រី —— ត្រូវបេះធ្វើម្ហូបអាហារ ៗ

## សំខ្យាគុណសព្ទ

## adjectif numéral

១ – ន័យ គឺដែលហៅថា សំខ្យាគុណសព្ទ? សំខ្យា-គុណសព្ទគឺសម្រាប់ដាក់ពីមុខនាមសព្ទដោយបញ្ជាក់នូវបរិមាណ ៗ

ដូចជា: ពាហានបីនាក់

ឬដោយបញ្ជាក់នូវថ្នាក់របស់ពួកមនុស្ស

ដូចជា: កថាភាគទី ២ -

២ – សមាសភាព

សំខ្យាគុណសព្ទ មានពីរគឺ:

ក). បកតិសំខ្យាគុណសព្ទ (adjectif numéral cardinal)

ខ). បូរណសំខ្យា គុណសព្ទ (adjectif numéral ordinal)

បកតិសំខ្យាគុណសព្ទគឺសំខ្យាដែលរាប់តាមប្រក្រតី ច្រើន

ចំនួនរបស់នាមថា ប៉ុណ្ណោះៗ ឬដឹងបរិមាណ គឺរាប់ថា មួយ, ពីរ, បី, បួន . . . . . .

បូរណសំខ្យា គុណសព្ទ គឺ សំខ្យាដែលរាប់នាមនាមបន្ត្រប់ជាជាន់ៗ តាមលំដាប់ តាមថ្នាក់គឺ រាប់ថា ទីមួយ' ទីពីរ, ទីបី, ទី-បួន, ទីប្រាំ ឬរាប់ថា '' ជាដំបូង, គំរប់ពីរ, គំរប់បី, គំរប់បួន ។

សេចក្ដីបញ្ជាក់: ដូចជាពាក្យថា ជ័យវរ្ម័នទីប្រាំពីរ, ជ័យ-ជេដ្ឋាទីពីរ, ថ្ងៃទី ១៦ មករា, ទំព័រសៀវភៅម្ភៃបួនៈ គុណសព្ទប្រាំពីរ, ដប់ពីរ, ម្ភៃបួន សុទ្ធតែបូរណសំខ្យា ។

## ៣ – ពាក្យកាព្យ

| | |
|---|---|
| សំខ្យាគុណសព្ទ | មានន័យថា |
| បកតិសំខ្យា | រាប់ប្រក្រតី |
| ឲ្យដឹងចំនួន | នាមជាអ្វី |
| ប្រកបសេចក្ដី | តាមបានា ។ |
| បូរណសំខ្យា | រាប់នាមនាម |
| បន្ត្រប់ទៅតាម | ជាន់អក្ខរា |

ថាក់មួយ ផ្លូវពីរ តាមបញ្ហា
ប្អូនអ្នកសិក្សា ឲ្យចាំស្ទាត់ ។

៤- ពាក្យសួរ- អ្វីដែលហៅថា សំខ្យាគុណសព្ទ? សំ-ខ្យាគុណសព្ទមានប៉ុន្មានយ៉ាង, អ្វីខ្លះ? ប្អូនពណ៌នា -

៥- វិធីហាត់សរសេរ

ប្អូនអ្នកដាក់ឫបូរណសំខ្យា ឬបកតិសំខ្យា ត្រង់គំនូសដែលគូសជាបន្ទាត់ ។

ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ________ ជាមហាក្សត្រិយ៍ សោយរាជនៅបន្ទាយលង្វែក ។

ព្រះបាទសម្ដេចជ័យវរ្ម័ន ____ ជាមហាក្សត្រ ទ្រង់បានស្ថាបនានូវប្រាសាទអង្គរ ។

មានមនុស្ស____ នាក់បានទៅមើលទាត់បាល ។

ប៉ាសួសទៅផ្សារបានទិញសៀវភៅចំនួន____ក្បាល ។

នាង៍ច័នថាទៅផ្សារទិញសំពត់ផ្កាចំនួន ____ ម៉ែត្រ

នាងសែម ឈរនៅផ្លូវទី ______

នាងឆោមរឹទ្ធ រៀនបានថ្នាក់លេខ ______

ទៅប៊ិន តែងប្រឡងជាប់សញ្ញាប័ត្របឋមសិក្សាលេខ ______

# សព្វនាម (Pronom)

១– និយ អ្វីដែលហៅថា សព្វនាម? សព្វនាម គឺ នាម ដែលមិនបញ្ជាក់ឈ្មោះសម្រាប់ប្រើចំពោះ មនុស្ស, សត្វ ឬ វត្ថុ ហើយដែលជំនួសនាមដែលគេពោលរួចមកហើយ ។

សព្វនាម គឺសព្ទដែលប្រើជំនួសឬជាជំនួយនាមនាម ។

ដូចជា: លោកសួនបានអញ្ជើញទៅផ្សារ, លោកបានទិញត្រី, បារី, ស្បែកជើង ។ លោកនេះជាសព្វនាម ។

ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រិយ៍ ប្រទេសកម្ពុជា ទ្រង់ជាអ្នកស្នេហាជាតិពិត ១ ។ ទ្រង់បានបំពេញព្រះរាជបេសកកម្មជុំវិញពិភពលោកសេរី, ដើម្បីទាមទារឯករាជ្យ ប្រទេសកម្ពុជា "ទ្រង់" ជាសព្វនាម ។

## ២– សមាសភាព

សព្វនាមមានប្រាំយ៉ាង:

ក) បុរិសសព្វនាម (*Pronom personnel*)

ខ) បច្ច័យសព្វនាម ( ,, *relatif*)

គ) បុច្ឆាសព្វនាម ( „ *interrogatif*)

ឃ) អនិយមសព្វនាម ( „ *indéfini*)

ង) និទស្សនៈសព្វនាម ( „ *démonstratif*)

## ៣– បុរិសសព្វនាម

បុរិសសព្វនាម មានន័យថាយ៉ាងណា ? បុរិសសព្វនាមមានន័យថាជាសព្វនាមសម្រាប់ប្រើចំពោះបុគ្គលទាំងបី គឺ បឋមបុរិសៈ, មជ្ឈិមបុរិសៈ, ឧត្តមបុរិសៈ ។

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| បឋមបុរិសៈ គឺ: | ខ្ញុំ | យើង |
| មជ្ឈិមបុរិសៈ គឺ: | ឯង | អ្នក |
| ឧត្តមបុរិសៈ គឺ: | គាត់<br>លោក | គាត់ទាំងអស់<br>លោកទាំងអស់<br>អ្នកស្រីទាំងអស់ |

ម្យ៉ាងវិញទៀត, បុរិសសព្វនាម គឺ សព្វនាមសម្រាប់ប្រើចំពោះបុគ្គល :

ក) ដែលពោល (បឋមបុរស:) គឺ ខ្ញុំ, យើង

ខ) ដែលគេពោលទៅកាន់វក (មជ្ឈិមបុរស:) គឺ ឯង, អ្នក;

គ) ដែលគេពោលពីមុនមក (ឧត្តមបុរស: គឺ: វា, គាត់,

វាទាំងអស់, គាត់ទាំងអស់ ។

## សព្វនាម (កាព្យពាក្យ៩)

សព្វនាមនេះ គឺនាមមិន - បញ្ចេញឈ្មោះ
ហៅចំពោះ មនុស្សសត្វ ឬវត្ថុ
ជំនួសនាម ដែលគេពោល ពីមុនទុក
ជំនួយមុខ នាមនាមពិត បណ្ឌិតពោល ។
ឯសព្វនាម ចែងញែកចេញ ប្រាំមួយយ៉ាង
បុរសសព្វ - នាមប្រាកដ ជាចំឡាក់គោល
ឯបច្ច័យ សព្វនាមគិត តាមពាក្យយោល
ទីបីមូល ហៅបុច្ឆា សព្វនាមអគ្គ ។
អនិយម - សព្វនាមពន្ស ជាទីបួន

ទីប្រាំបួន ហៅសាមី - សមុទ្រទ្រង់

ទីប្រាំមួយ និងស្បែន: សព្វនាមវង្ស

វិធីផ្តិតផ្ទង់ រៀនឲ្យចាំ និស្សិតអើយ ។

# វិធីហាត់សរសេរ

១ – ឲ្យសរសេរនៅក្នុងខ្សញ្ញា ( វង់ក្រចក ) ក្រោយសព្វនាមទីមួយ ៗ , នូវនាមសព្ទដែលជំនួសសព្វនាម ។

នាងសំ ជានារី ប្រកបដោយរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ, នាងនេះជិះទោចក្រយានទៅរៀនអនុវិទ្យាល័យ នារី, នាងមានមិត្តម្នាក់ នាមនាង បន្ទុតាក ។ នាងទាំងពីរនាក់ទៅរៀនសាលាបានជួបប្រទះនឹងអ្នកគ្រូ នាមនាង មន្ទា ។ អ្នកគ្រូនេះប្រាជ្ញាឆ្លាតពន់វៃប៉ិនប្រសប់ខាងរកវិធីអប់រំកូនសិស្សឲ្យរៀនឆាប់ចេះចាំ ។

នាងសំ ជាស្ត្រីព្យាយាមរៀនសូត្រ, នាងនេះទើបអាយុ ១៣ ឆ្នាំ ក៏ប្រឡងជាប់វិញ្ញាបនបត្របឋមសិក្សា ។

នាងបន្ទុតាកមានស្មារតីពូកែរៀនវិជ្ជាឆាប់ចេះចាំ ។ នាងនេះ

តាមគេធ្លាប់ជឿតៗមកថា នាងបានចាំច្បាប់ក្រមនឹងកេរ្ដិ៍កាលតាំងពី នាងអាយុ ៩ ឆ្នាំ ។

៦ — ឲ្យដាក់សញ្ញាសម្គាល់ គឺ: គូសមួយពីក្រោមចំពោះ បឋមបុរិស:, គូសពីរពីក្រោមចំពោះ មជ្ឈិមបុរិស:, គូសពី ក្រោមចំពោះ ឧត្តមបុរិស: ។

## គេហដ្ឋានខ្ញុំ

ខ្ញុំមានគេហដ្ឋានមួយនៅខាងលិចសាលាគរុវិជ្ជាខាងត្បូង ។ គេហដ្ឋាននេះស្ថិតនៅមាត់វិថី ប៉ាស្ទ័រ (ភ្នំពេញ) ។ ខ្ញុំមានបងប្អូននៅជាមួយគ្នានឹងគេហដ្ឋាននេះពីរនាក់ ។ យើងទាំងពីរនេះទៅណាមកណាជាមួយគ្នា ។ បងខ្ញុំគាត់នៅបន្ទប់ខាងមុខ ខ្ញុំនៅបន្ទប់កណ្ដាល បន្ទប់មួយទៀត ខ្ញុំជួលឲ្យលោកសួនអ្នកស្រីស្អាតនៅ ។ មានមួយថ្ងៃ ខ្ញុំពោលទៅកាន់អ្នកស្រីថា អ្នកស្រីនៅជាមួយនឹងខ្ញុំគ្មានផុលរមាស់សោះឡើយឬ? ។ ខ្ញុំឥតស្អុះស្អាប់ទេ ព្រោះបើអ្នកទាំងអស់នេះដែលមកនៅជ្រកកោនក្រោមម្លប់លោក, បើមានចិត្តសន្ដោសទៅវិញទៅមក មុខជាយើងទាំងអស់គ្នានឹងបានសុខមិនខាន ។

៣– ត្រូវតែចេះប្រើបុរិសសព្វនាម

ត្រូវសរសេរអត្ថបទមួយ ហើយដាក់បុរិសៈសព្វនាមឲ្យត្រឹមត្រូវ

៤– ចូរអ្នកបំពេញនូវសេចក្តីខាងក្រោមជាគំរូ ហើយដាក់ជាពាក្យសួរ ឆ្លើយ ដូចគ្នាបាន ៦ ប្រយោគ:

ឧទាហរណ៍: ឯងមានទិញសៀវភៅលោកសួនឬទេ? បាទខ្ញុំបានទិញសៀវភៅនេះ ទេខ្ញុំមិនបានទិញសៀវភៅនេះទេ ។

៥– ពាក្យសួរ អ្វីដែលហៅថា សព្វនាម? សមាសភាពមានប៉ុន្មាន? អ្វីដែលហៅថា បុរិសសព្វនាម? ឧទាហរណ៍ –

## បច្ច័យ សព្វនាម

### (Pronom relatif)

១– ន័យ បច្ច័យសព្វនាមគឺ នាមដែលគេលើកទៅដាក់ពីមុខប្រយោគជាជំនួសនាម ឬ សព្វនាមនៃប្រយោគមុន, ហើយមាន បច្ច័យទាក់ទងនឹងនាម ឬ សព្វនាមនេះទៅនឹងប្រយោគដែលនាម ឬ សព្វនាមស្ថិតនៅ ។

ដែលគេហៅថា បច្ច័យសព្វនាមគឺសព្វនាមសម្រាប់ប្រើត -

ភ្ជាប់ពាក្យដែលសព្វនាមនោះជំនួសទៅនឹងសព្វនាម ដែលស្ថិតនៅពីក្រោយ ។ ឧទាហរណ៍: ដែល

ស្រីដែលខ្ញុំឃើញមានប្រាជ្ញាថ្លាតវាងវៃ ។

ឯបច្ច័យសព្វនាមនោះគឺ: ដែល, សត្វគោដែលខ្ញុំជួបប្រទះមានសម្បុរក្រហម, ចោរដែលខ្ញុំឃើញ គឺ ពួកអ្នកស្រុកនៅក្នុងភូមិខ្ញុំ ។

ស្រីដែលខ្ញុំឃើញ ជាភរិយាមន្ត្រីធំ ។

នារីដែលដើរតាមផ្លូវជាកូនសិស្សសាលា ។

ស្រីដែលនៅបម្រើគេមិនដែលបានអាហារឆ្ងាញ់ពីសាមីភោគទេ ។

## ២- ពាក្យកាព្យ

| | |
|---|---|
| បច្ច័យសព្វនាម | នាមយកដាក់ |
| ពីមុខស្មោះស្ម័គ្រ | ប្រយោគមាន |
| សម្រាប់តភ្ជាប់ | ពាក្យតាមស្ថាន |
| ជំនួសនាមប្រាណ | តាមត្រូវការ ។ |

## ៣ - វិធីហាត់សរសេរ

ឲ្យជំនួស គំនូស គូសជាបន្ទាត់ដាក់បច្ច័យសព្វនាម ។

មនុស្ស ———— ខ្ញុំឃើញជានិស្សិតសាលាគរុវិជ្ជា ។

មនុស្ស ———— សេពគប់នឹងបណ្ឌិតមុខជាក្លាយទៅជាបណ្ឌិត ។

កូនក្មេង ———— គេបង្ហាត់បង្ហាញជាកូនសេដ្ឋី ។

ទ្រព្យសម្បត្តិ ———— យើងខំរកមិនបានស្ទើរតែសោះឡើយ ។

ការហាត់ប្រាណ ————អ្នកប្រមុងនឹងធ្វើនាំឲ្យមានសុខភាពដល់អ្នក ។

អ្នកណា ————ចង់បានទាំងអស់បានទទេ ។

៤- ពាក្យសួរ អ្វីដែលហៅថា បច្ច័យសព្វនាម. ឧទាហរណ៍ -

## បុច្ឆាសព្វនាម

**(Pronom interrogatif)**

១- ន័យ- មានសព្វនាមខ្លះសម្រាប់សួរគ្នាទៅវិញ-មក,

បានជាខ្ញុំឲ្យនាមថា បុច្ឆាសព្វនាម (ពាក្យនេះគឺសទ្ទតហៅបណ្ដោះអសន្ន ខ្ញុំកំមានពាក្យសម្រេចពីគណៈកម្មការវប្បធម៌) ។

ដូចជាថា :

តើអ្នកចង់បានអ្វី ?

តើអ្នកយល់យ៉ាងណា ?

អ្នកមកតើមានការអ្វី ?

អ្នកណា ខ្លះ ?

អ្នកណាដើរ ខ្លះ

តើ, ខ្លះ ជាបុច្ឆាសព្វនាម ។

ហេតុអ្វីក៏អ្នកមករកខ្ញុំ ?

ហេតុដូចម្ដេចបានជាអ្នកមិនសួរខ្ញុំ ?

## ២- ពាក្យកាព្យ (ពាក្យ ៧)

| | |
|---|---|
| បុច្ឆាសព្វនាម | សម្រាប់សួរ |
| និស្សិតគាប់គួរ | ខំទន្ទេញ |
| ឲ្យចាំចំគួចង | មូលជិតវេញ |

ខំពោលចូលចេញ ឲ្យចាំស្ទាត់ ៗ

៣ – <u>វិធីហាត់សរសេរ</u> .– ចូរដាក់បុច្ឆាសព្វនាម ត្រង់កន្លែងដែលគូសៈ បន្ទាត់ៈ

—— អ្នកពោលរឿងអ្វី?

—— អ្នកឯងនាមអ្វី ?

—— កូនអ្នកឈ្មោះអ្វី ?

—— អ្នករៀនដល់ថ្នាក់ណា ?

—— ក៏អ្នកមករកខ្ញុំ ?

—— ក៏អ្នកខំធ្វើការដូចនេះ ?

អ្នកណាច្រៀង ——

អ្នកណាពោល ——

៤ – <u>ពាក្យសួរ</u> អ្វីដែលហៅថា បុច្ឆាសព្វនាម? ឧទាហរណ៍-

## អនិយមសព្វនាម

**(Pronom indéfini)**

១– <u>ន័យ</u> ដែលហៅថាអនិយមសព្វនាម គឺសព្វនាមដែល

ហៅ បុគ្គល , សត្វ ឬវត្ថុ មានលំនាំមិនសូវច្បាស់លាស់ , មាន សភាពទូទៅ, អនិយម ។

ឧទាហរណ៍ ដូចជា: គេ, ម្នាក់ៗ , បុគ្គល, អ្នកឯទៀត, អ្នកណា, គ្មាន, អ្នកនោះ, មនុស្សខ្លះ ។ល។

គេទៅផ្សារ ។

មនុស្ស – មានគេ – មានប្រាជ្ញាជាមូលដ្ឋាន ។

មនុស្សម្នាក់ៗ មានសិទ្ធិនិងករណីយកិច្ចគ្រប់ៗគ្នា ។

គ្មានអ្នកណាចៀសនូវបាបអកុសលបានទេ ។

## ២– ពាក្យកាព្យ (បទកាកគតិ)

ហៅអនិយម សព្វនាមឧត្តម គឺសព្វនាម

សម្រាប់ហៅភាព មនុស្សសត្វក្តាម វត្ថុជានាម

សភាពមិនច្បាស់ ។

## ៣– វិធីហាត់សរសេរ

សត្វសុនខមាន ——ជាសត្វមានគន្ធារម្មណ៍ យ៉ាងមុះមុត ។

មនុស្សគំណាញ់មិនចូលចិត្ត —— ទេ ។

—— ខ្ជិល —— សុខ ។

មនុស្សសប្បុរសពិចារណាគុណវិបត្តិ —— តែ ——
ពោលអាក្រក់អំពីអ្នកណាទេ ។

—— មិនបេះអុតអាងទេ ។

៤ – ពាក្យសួរ អនិយមសព្វនាមបានន័យថាយ៉ាងណា ?
តើមានអ្វីខ្លះ? ចូរធ្វើប្រយោគមួយដែលមានអនិយមសព្វនាម -

## និទស្សនៈសព្វនាម

## (Pronom démonstratif)

១ – ន័យ និទស្សនៈសព្វនាម គឺ សព្វនាមដាក់ជំនួសនាម
ដោយចង្អុលបង្ហាញនូវបុគ្គល, សត្វ, វត្ថុ ដែលគេពណ៌នា ។

ឧទាហរណ៍: នុះ និងសៀវភៅខ្ញុំ

ឯណោះនិង, កន្លែងខ្ញុំ

២ – ពាក្យការព្យ (បទព្រហ្មគីត)

និទស្សនៈនេះ បណ្ដិតចេះ តែងពោលថា

សព្វនាមសម្រាប់ណា ជំនួសនាម ពិតប្រាកដ ។ ដោយបង្ហាញបង្អុល ស្គាល់ឬសគល់ តាមសន្មត បុគ្គល វត្ថុ សត្វ ដែលគេ បាត់ពណ៌នា ។

៣ = វិធីហាត់សរសេរ

—— ផ្ទះខ្ញុំ

—— កៅអីដែលគេឱ្យខ្ញុំ

—— ផ្ទះលោកចៅហ្វាយខេត្ត

—— ផ្លូវទៅផ្សារថ្មី

៤ = ពាក្យសួរ យ៉ាងដូចម្ដេចដែលហៅថា និទស្សនៈ សព្វនាម? ឧទាហរណ៍ ។

## កិរិយាសព្ទ
## (Verbe)

១– ន័យ កិរិយាសព្ទ គឺសព្ទដែលសម្រាប់បញ្ជាក់ថា គេ មានភាពយ៉ាងណា ឬគេធ្វើអ្វី ។

ឧទាហរណ៍: មនុស្សជាសត្វមានប្រាជ្ញា

មានគឺ គេកំណត់ហៅថាភាព

—— សេះទាញរទេះ

ទាញ គឺគេកំណត់ថាសកម្មភាព

កិរិយាសព្ទបញ្ជាក់ជាភាព (états) ឬជាសកម្មភាព (action).

គេអាចសំគាល់បានថាពាក្យនេះជាកិរិយាសព្ទបាន លុះត្រាតែអាចដាក់សព្ទនាមពីមុខពាក្យនោះ តាមគួរការដូចជាសព្ទនាម : ខ្ញុំ, ឯង, គាត់, យើង, អ្នក, អ្នកទាំងអស់ ។

## ២ - ពាក្យកាព្យ (កាព្យពាក្យ ៧)

កិរិយាសព្ទ　　គឺជាសព្ទ
ពាក្យដែលសម្រាប់　　ជាមានភាព
ឬគេធ្វើ　　ប្រាជ្ញគេប្រាប
តាមកិច្ចខ្ពស់ទាប　　យល់តាមការ ។

## ៣ - វិធីហាត់សរសេរ

ក) តើតួនាទីក្រោមមានសកម្មភាពយ៉ាងណាខ្លះ?

គំរូ : ផ្ទះ　ផ្ទះសម្រាប់នៅ

សេះ, ឆ្កែ, ផ្លូវ, ផ្សារ, គោ, ក្របី, ចោរ, កន្ត្រៃ, រថយន្ត, កណ្តុរ, ខ្នុរ, ខ្សែ, ខ្សៀ, ស្លាបប៉ាកា, កាំបិត, ខ្មៅដៃ, បន្ទាត់, ទន្ត័ល, រនាស់, ម្ហូបអាហារ, ដើមឈើ, ដៃ, ជើង, ក្បាល ។

ខ) តើគេហៅសត្វអ្វីដែលមានសកម្មភាពដូចខាងក្រោម:

ហើរ, ហែល, លូន, លូឬព្រុស, និយាយ, ស្រែក, យំ, ច្រៀង ។

គ) ចូរដាក់ត្រង់គំនូសគូសជាបន្ទាត់នូវកិរិយាសព្ទតាមគួរការ ។

ទឹកសម្រាប់ ___, ផ្លូវគេតែង ___, ភាពយន្តគេតែង ទៅ ___, ចោរគេតែង ___ កៅអីសម្រាប់ ___

ខោអាវសម្រាប់ ___ ផ្កាសម្រាប់ ___ គ្រូត្រូវតែ ___

មួកត្រូវតែ ___ ត្រចៀកត្រូវការ ___ ដៃត្រូវការ ___

មាត់ត្រូវការ ___ ដំណើរត្រូវការ ___ សៀវភៅសម្រាប់ ___

ពាក្យទូន្មានចាស់ព្រឹទ្ធាចារ្យត្រូវតែ ___

## ៤– អត្ថរបស់កិរិយាសព្ទ (Formes)

កិរិយាសព្ទមានអត្ថពីរយ៉ាងគឺ :

ក). អត្ថ កត្តុវាចក: (*forme active*)

ខ). អត្ថ កម្មវាចក: (*forme passive*)

អត្ថ កត្តុវាចក: ដូចជា, ក្របីស៊ីស្មៅ, មាន់ស៊ីគ្រាប់ពោត

អត្ថ កម្មវាចក: ស្មៅដែលក្របីស៊ី, គ្រាប់ពោតដែលមាន់ស៊ីៗ

## ៤ បុរិស (Personne)

បុរិសមានបីគឺ:

ក). បឋមបុរិស

ខ). មជ្ឈិមបុរិស

គ). ឧត្តមបុរិស

| បុរិសនេះមានជា ឯកវចនៈ: **(Singulier)** | ជា ពហុវចនៈ: **(Pluriel)** |
|---|---|
| ឧទាហរណ៍: ខ្ញុំទៅផ្សារ | យើងទៅផ្សារ |
| ឯង —— | អ្នក —— |
| គាត់ —— | អ្នកទាំងអស់ —— |

## ៦ កាល.

កាលមានបួនគឺ:

ក). អតីតកាល (Passé Composé)

ខ). បច្ចុប្បន្នកាល (Présent)

គ). អនាគតកាល (Futur)

ឃ). អតីតានាគត (Futur conditionnel)

ឧទាហរណ៍ ខ្ញុំទៅផ្សារ (បច្ចុប្បន្នកាល)

ខ្ញុំបានទៅផ្សារ (អតីតកាល)

ខ្ញុំមុខនឹងទៅផ្សារ (អនាគតកាល)

ខ្ញុំប្រហែលនឹងទៅផ្សារ (អតីតានាគត)

៧ — ប្រធាន, កម្ម, អកម្ម

ដែលហៅថា ប្រធានគឺពាក្យដែលដាក់ពីមុខកិរិយាសព្ទ

ខ្ញុំទៅធ្វើការ ឯសាលាឃុំ

ខ្ញុំជាប្រធានរបស់ទៅ,

ទៅជាកិរិយារបស់ខ្ញុំ

ធ្វើជាកិរិយាប្រាប់ដំណាន៍របស់ទៅ (ទៅដើម្បីធ្វើ) ការជាអំពើរបស់ធ្វើ

ឯសាលាឃុំ ជាអយតនិបាតប្រាប់ទី (ដែលត្រូវធ្វើការ)

ខ្ញុំទៅផ្សារ

ផ្សារជាកម្មរបស់ទៅ

ក្មេងញញឹមទៅកាន់មាតា -

មាតាជាអកម្មរបស់ទៅ

៨). ពាក្យសួរ. អ្វីហៅថា កិរិយាសព្ទ - ឧទាហរណ៍ -

អត្ថនៃកិរិយាសព្ទមានប៉ុន្មាន? អ្វីខ្លះ?

បុរសមានប៉ុន្មានយ៉ាង? បូរពណ៌នា -

កាលមានប៉ុន្មានយ៉ាង? អ្វីខ្លះ? បូរអធិប្បាយ -

## កិរិយាវិសេសន៍

## Adverbe

១– ន័យ. កិរិយាវិសេសន៍ គឺពាក្យជាអនិច្ចភាព (invariable)

ដែលធ្វើឲ្យប្រែប្រួលនៃកិរិយាសព្ទ, គុណសព្ទ ឬកិរិយាវិសេសន៍ឯទៀត ។

ឧទាហរណ៍: ម៉េងដើរលឿន

សត្វកណ្ដុរជាសត្វរត់លឿនណាស់ តែមិនផុតពីជើងឆ្មា -

២ - សមាសភាព - កិរិយាវិសេសន៍នោះមានជាច្រើនយ៉ាងគឺ: កិរិយាវិសេសន៍ស្ថានទី ១, កិរិយាវិសេស តាមកាល ១, កិរិយាវិសេសន៍ តាមចំនួន ១, កិរិយាវិសេសន៍តាមលំនាំ ឬការប្រៀបធៀប ១, កិរិយាវិសេសន៍ មានន័យជាព្រម ឬ សង្ស័យ ១, កិរិយាវិសេសន៍ មិនព្រម ១,

កិរិយាវិសេសន៍ តាមកាលគឺ: ឯណោះ, ឥឡូវនេះ, ពីមុន, ក្លាយ, ពីដើម, មុន, បន្តិចទៀត, រួចហើយ, ស្អែក, អវសាន, បន្ទាប់តមក, ម្សិលមេញ, មិនដែល, ប្រហែល, កាលណា, ម្ដង ៗ, ញឹកញយ, យឺត, ឆាប់ . . . . . ល . . . .

កិរិយាវិសេសន៍ ស្ថានទីគឺ: ជុំវិញ, នេះ, នោះ, ខាងក្នុង, ខាងក្រៅ, ខាងក្រោយ, ខាងលើ, ខាងក្រោម, ខាងមុខ, ឯនេះ,

ឆ្ងាយ, ទាំងអស់. . . . . ល . . . . ។

កិរិយាវិសេសន៍ តាមចំនួនគឺ: ប៉ុណ្ណោះហើយ, ច្រើន, តិច, ប៉ុន្មាន, ទៀត, ដូចជា, ណាស់, . . . . ល . . . ។

កិរិយាវិសេសន៍ តាមលំនាំឬតាមសេចក្ដីប្រៀបធៀបគឺ: ហេតុម្ដេច, ជាមួយគ្នា, ខ្លាំងវិសេស, រហ័ស . . . . ល . . . ។

កិរិយាវិសេសន៍តាមសេចក្ដីព្រមឬសង្ស័យគឺ: ប្រាកដមែន, ប្រហែល ។

កិរិយាវិសេសន៍ តាមសេចក្ដីមិនព្រមគឺ: ទេ, មិនបានទេ, គ្មានទេ, មិនមែនទេ, . . . ល . . . ។

## ៣- ពាក្យកាព្យ (ពាក្យ៧)

កិរិយាវិសេសន៍ អនុប្បភាព
ពួកបណ្ឌិតគួរជ្រាប សត្វដែលរចនា
ប្រែប្រួលកិរិយាសព្ទ តាមអក្ខក
គុណសព្ទណា កិរិយាវិសេសន៍ ។

## ៤-- កិរិយាវិសេសកវបទៈ (Locution adverbiale)

កិរិយាវិសេសកវបទៈ គឺពាក្យប្រកបកិរិយាវិសេសន៍ ឬពាក្យប្រមូលច្រើនសម្រាប់ប្រើជាកិរិយាវិសេសមាន :

ពាក់កណ្ដាល, ប្រហែល, ខានស្អែក, ឥឡូវនេះ, គួរស្ដាយ សែនស្ដាយ, ខាងក្រៅ, ខាងក្នុង, ខាងលើ, ខាងក្រោម, សែនឆ្ងាយ, ខាងនោះ, ម្សិលមិញ, ពេលថ្មីៗ, លំដាប់តមក, ពេលជាមួយ, ប្រូកប្រល់, បន្តិចៗ, ត្រូវនិយាយបែបនេះ, មិនឈប់ឈរ, ពីក្រោមទៅលើ ។ល។

## ៥– វិធីហាត់សរសេរ ពាក្យដែលថា

ក) ចូរគូសកិរិយាវិសេសន៍ និងកិរិយាវិសេសកវបទៈ ក្នុងប្រយោគខាងក្រោមនេះ ។

— មានគេនិយាយច្រើនណាស់ហើយគិតតិចណាស់

— ព្រះចន្ទស្ថិតនៅឆ្ងាយបន្តិច បើធៀបចម្ងាយពីផែនដីទៅកាន់ព្រះអាទិត្យ ។

— ឆ្មាមិនប្រសប់នៅស្ងប់ស្ងៀមគួរឲ្យស្ញប់ស្ញែង, មុននឹងចាប់កណ្ដុរ ។

— សម្ដេចនរោត្ដមសីហនុឧបយុវរាជ ទ្រង់បានកសាងឯក-រាជប្រទេសកម្ពុជា ដោយពេញលេញ ។

— សាច់ពពែមានសភាពឆ្ងាញ់ជាងសាច់គោ ។

— ត្រូវគោរពយ៉ាងម៉ឺងម៉ាត់ចំពោះមាតាបិតា គ្រូអាចារ្យ ។

— កូនសិស្សអាក្រក់ពោលថាគេធ្វើទោសវាដោយអយុត្តិធម៌ ។

— ខាងក្រៅគេហដ្ឋានរបស់ខ្ញុំមានសួនច្បារ ។

ខ) បើគេដាក់កិរិយាវិសេស នឹងកិរិយាវិសេសិកវចនៈហើយ ត្រូវរកពាក្យធ្វើប្រយោគឲ្យត្រឹមត្រូវ ។

ដោយស្ងាត់, សែនស្ដាយ, សែនអាល័យ, សែនស្រណោះ, ដោយខ្លាំង, ដោយសច្ចៈ, ខាងនោះ, ពេលថ្មី, ដោយស្រួល, ដោយងាយ, ដោយលំបាក, ដោយជ្រៅ, ខានស្អែក, ឥឡូវនេះ, គួរស្ដាយ ។

៦– <u>ពាក្យសួរ</u>. អ្វីដែលហៅថា កិរិយាវិសេស? ចូរពណ៌នា ។

កិរិយាវិសេសឯកវចនៈ ផ្ទានន័យថា យ៉ាងណា ? អ្វីខ្លះ ? ។

## អាយតៈនិបាតសព្ទ préposition

១ – ន័យ. អាយតៈនិបាតសព្ទ គឺពាក្យដែលសម្រាប់ភ្ជាប់ពាក្យពីរដោយបញ្ជាក់ឲ្យសមាភាគនៃពាក្យនោះទៅវិញ-មក ។

ឧទាហរណ៍: ខ្ញុំទៅឯកំពង់ឆ្នាំង អាយតៈនិបាតសព្ទ ( ឯ ) ភ្ជាប់កិរិយាសព្ទ ( ទៅ ) ចំពោះនាមសព្ទ ( កំពង់ឆ្នាំង ) ។

អាយតៈនិបាតសព្ទគឺ: ឯ, ក្រោយ, មុខ, ជាមួយចំពោះ, ក្នុង,ពីកាលនោះ, រវាង, វៀរលែង, ក្រៅពីនេះ, ទៅកាន់, ទុ៎ះន, . . . ល . . .

២ – អាយតៈនិបាតសព្ទករិបទ: *(locution prépositive)* ដែលគេហៅថា អាយតៈនិបាតសព្ទកវចនៈនោះគឺសំណុំពាក្យដែលមានសភាពដូចអាយតៈនិបាតសព្ទ ។ អាយតៈនិបាតសព្ទក

វចនៈនោះគឺៈ ដោយហេតុ, នៅជិតនោះ, ដើម្បីនឹង, ដោយសេចក្ដី អនុគ្រោះពី, ខាងលើ, ខាងមុខ, ខាងលើ, ចំកណ្ដាល; ជុំវិញ; ខ្លាចក្រែង, ដល់ទៅ, . . . ល . . .

## ៣ – ពាក្យកាព្យ (បទកាកគតិ)

អាយតៈនិបាត លោកគ្រូឱ្យទ
សម្រាប់ភ្ជាប់ពាក្យ ដោយបញ្ជាក់នូវ ភាពសមាភាគ
នៃសព្ទសួរសាក បច្ច័យពាក្យពិត ៗ អាយតៈនិ-
បាតសព្ទិ- កវចនៈពិត ដែលមានសភាព
និបាតសព្ទជិត ប្រកបណៃបនិត ចូរបាចងចាំ ៗ

## ៤ – វិធីហាត់សរសេរ

ចូរអ្នកគួសបន្ទាត់ចំពោះអាយតៈនិបាតសព្ទ ឬ អាយតៈនិបាតសព្ទិកវចនៈដែលមានក្នុងប្រយោគនេះ ៗ

—— ពួកកម្ពុជៈ (ប្រទេសឥណ្ឌា) បានដំរង់តាមសមុទ្រទៅកាន់នគរគោកធ្លក

—— ព្រានរត់ពីក្រោយគម្រិត ។

—— សេះរត់ពីមុខគោ ។

—— ខ្ញុំយល់ថាមនុស្សនេះល្អ វៀរលែងតែគាត់ផឹកស្រា ចិត្តគាត់កាចបន្តិច ។

—— ខ្ញុំទៅជាមួយបងខ្ញុំទៅសួរមា ។

—— ខ្ញុំកើតឯស្រុកស៊ីសុផុន ។

—— ដោយហេតុថាឈ្មោះនេះមិនសូវនិយាយស្តី បានជាគេសន្ស័យជានិច្ច ។

—— ពីកាលនោះខ្ញុំនៅក្មេងនៅឡើយ ។

—— ដើម្បីនឹងធ្វើដំណើរទៅតាមបើកគោកគេប្រើរថយន្តឬ អយស្ម័យយាន ។

—— ជុំវិញគេហដ្ឋានខ្ញុំមានសួនច្បារ ។

៨ – <u>ពាក្យសួរ</u> គាយកៈនិបាតសព្ទ បានន័យថាយ៉ាងណា? អ្វីខ្លះ?

តើ គាយកៈនិបាតសព្ទិកវចនៈ បានន័យថាយ៉ាងណា? អ្វីខ្លះ? ចូរអធិប្បាយ ។

## សន្ធានសព្ទ Conjonction

១ – ន័យ. សន្ធានសព្ទ គឺពាក្យសម្រាប់ភ្ជាប់ប្រយោគពីមួយទៅមួយ ឬ ផ្នែកប្រយោគពីមួយទៅមួយ ។ ឧទាហរណ៍: គេមិនអាចជឿគ្រូន័បាន បើគ្រូន័នោះធ្លាប់កុហកម្តងហើយ ។ ថ្ងៃនេះ ទីន់ថ្ងៃស្អែកជាពេលបុណ្យ ។

"បើដែល" ភ្ជាប់ប្រយោគ: "គេមិនអាចជឿគ្រូន័បាន" ទៅនឹងប្រយោគ: "គ្រូន័នោះធ្លាប់កុហកម្តងហើយ" គេហៅថា សន្ធានសព្ទ ។

ទីន់ដែលភ្ជាប់ប្រយោគ ឬ ពាក្យ "ថ្ងៃនេះ" ទៅនឹងប្រយោគ "ថ្ងៃស្អែកជាពេលបុណ្យ" គេហៅថា សន្ធានសព្ទ ។

២ – តើអ្វីខ្លះ ដែលហៅថា សន្ធានសព្ទ? សន្ធានសព្ទគឺ: ដូចគ្នា, ពីព្រោះ, បើដូច្នេះ, ទីន់, កាលណា, តែ, ពិតមែន ឬដោយហេតុថា, បើដូច្នោះ, បើមិនដូច្នោះទេ, ល . . . .

### ៣ – ពាក្យកាព្យ.

សន្ធានសព្ទ គឺពាក្យប្រាកដ សម្រាប់ភ្ជាប់គ្នា

ប្រយោគពីមួយ ទៅប្រយោគ    តាមពេល

អក្ខុក    ចូរបាចង់ចាំ ។

## ៤ – សន្ធានសព្ទិកវិបទៈ (Locutionconjonctive)

ដែលគេហៅថា សន្ធានសព្ទិកវបទៈ គឺ សំណុំពាក្យមានកិច្ច បំពេញជាសន្ធានសព្ទ ។ សន្ធានសព្ទិកវបទៈគឺៈ

ដោយហេតុថា ល្គឹកបើ ពីព្រោះតែ, បើសិនណាជា, ក្រោយកិច្ចដែរ, ដោយវិចារណញ្ញាណថា, ក្នុងមួយរំពេចដែរ . . . ., តាំងតែពីកាល . . ., ដោយហេតុដូចនេះ, ពិតមែនតែ, គឺថា' ដូចគ្នានឹង, ទាល់តែ . . . ល . . . ។

## ៥ – វិធីហាត់សរសេរ

ក). ចូរគូសគំនូសខាងក្រោមពាក្យណាដែលជាសន្ធានសព្ទ ឬសន្ធានសព្ទិកវបទៈ ។ អាកាសពាល់មិនបាន តែមានទម្ងន់ ដូចជារបស់ឯទៀត ។

ចូរអ្នកខំធ្វើការ គង់តែអ្នកនឹងបានសុខ, សម្តេចព្រះនរោត្តម

សីហនុ ឧបយុវរាជទ្រង់បានកសាងឯកភាព ប្រទេសកម្ពុជា ព្រោះតែទ្រង់ស្នេហាជាតិមាតុភូមិ ។

ត្រូវពត់ចរិយាពីក្មេងដូចជាគេពត់ឫស្សីពីទន់ដូចនោះ ។

អ្នកមាន ឬ អ្នកក្រ ត្រូវតែមានកេរ្តិ៍ដំណែល ។

ទន្លេមេគង្គ ពិតមែនតែធំ ហើយវែងតែមិនអាចនឹងប្រៀបធៀបនឹងទន្លេនីលបានទេ ។

មិត្តល្អឃើញយើងមានទុក្ខមកជួយឧបត្ថម្ភ, បើយើងបានសុខនៅស្ងៀមប្រងើយឯគេហដ្ឋាន ។

ពេជ្រកម្រនឹងរកបាន, ព្រោះហេតុដូច្នេះបានជា ថាពេជ្រមានតម្លៃណាស់ ។

១). ឲ្យយកសន្ទានសព្ទដាក់ត្រង់បន្ទាត់ដែលគូស ។

ប្រទេសកម្ពុជាមានពលរដ្ឋតិចជាងប្រទេសថៃឡង់ – មានពលរដ្ឋច្រើនជាងប្រទេសឡាវ ។

បុគ្គលដែលធ្វើបាបអកុសលគង់ទទួលទោសជាប់ – ដែលពេលណាមួយមិនខាន ។

ទន្លេសាបរួមស្ទឹងសង្កែទន្លេមេគង្គ ។

ព្រះចន្ទព្រះធរណីបានទទួលរស្មី ពីព្រះអាទិត្យ ។

ចូរអ្នកប្រតិបត្តិតាមច្បាប់ – អ្នកបង់ឲ្យប្រទេសចម្រើន ។

សម្តេចនរោត្តមសីហនុព្រះឧបយុវរាជទ្រង់បានកសាងឯករាជ្យប្រទេសកម្ពុជាដោយសម្បូរណ៍ – ស្ថាបនានូវសង្គមរាស្ត្រនិយម ។

ចូរអ្នកចំរើនកុសល – ជីវិតមិនទៀង ។

៦ – <u>ពាក្យសួរ</u>. សន្ធានសព្ទបានន័យថាយ៉ាងណា ? អ្វីខ្លះ? សន្ធានសព្ទិកវចនៈបានន័យជាដូចម្តេច ? អ្វីខ្លះ? ចូរអធិប្បាយ ។

## ឧទានសព្ទ Interjection

១– <u>ន័យ</u> ឧទានសព្ទ គឺជាពាក្យសម្រាប់បញ្ជាក់នូវសេចក្តីរសើរ, សេចក្តីសប្បាយ, សេចក្តីទុក្ខ, សេចក្តីឆ្ងល់សង្ស័យ ។ល។

ឧទានសព្ទ គឺ: ឱ!, អា! អ៊ុយ!, យី!, ខ្ជប ៗ, បេប ៗ, ញ៎!, អៃ!, អេ!, អ្ហ!, អា!, អ្ហះ!, អ្ហា!, អ្ហឺ! អ្ហូ!, អ្ហុះ,

អ្ហោ!, អោះ!, យ៉ើ!, យោ!, យើ!, យើះ!, យ៉ូយ!, យើ!, ហា! ។ល។ ដែលគេហៅថា ឧទានសព្ទកវចនៈ (locution interjective) គឺសំណុំពាក្យដែលរៀបរៀមមកសម្រាប់ប្រើ ដូចជា ឧទានសព្ទគឺ: អា! អ៊ុហ៎!, អា! ដូច្នោះទេឬ?, អា! អញ្ជើញមក!, ពិបាកអម្បាយហ៎!, គួរអនិច្ចាណាស់ហ៎!, អុញ! កំពប់អស់រលីង, អុញន៎! គេថាកុំៗមិនស្តាប់!, ឥឡូវមិនខុសពីមាត់ថា!, អៃយ៉ា!, អៃយ៉ូ!, អៃយូយ!, អៃយ៉ូះ!, អៃយ៉!, ណ្ហើយ! ឯងត្រឹមនឹងប៉ុះ!, ឱ! រូបអើយរូប! អេ៎! ដូច្នោះទេឬ?, ឧហ៎!, អើហ៎!, សូមទានឧកាស!, ឱ! ពុទ្ធោ ពុទ្ធោ!, អ្ហ! កុំអាលស៊ិន!, អ្ហា៎! កុំមិនបានបានទេ!, អ្ហះ! ទៅឯណាទៅវិញ ឆ្កុយ! អ្ហាះ៎! ថាម៉េច?, ស្អែកមកកុំខាននឹ! អ្ហូ! អើប៉ុះទេឬ អ្ហូះ! អញមិនរវល់ទេ!, អ្ហោ! ទៀតហើយ!, អ្ហោ! បែកកែវហើយ!, អ្ហ! ថាម៉េច? យើ! អីគេស្តីឲ្យម្លឹងហើយនៅតែមិនទាន់ដឹងខ្លួន!, យោ! ថ្លៃណាស់តើ!, យើ! ល្អណាស់តើហ៎!, យើះ! មិនសមដល់ម្លឹងសោះ!, ស្រែកយ៉ូយ!, យូយដែរ!, យើ! ខ្លាចណាស់!,

ះសើចហាស់ ៗ ៗ ល ៗ

## ២ កាព្យ (ពាក្យ៧)

ឧទានសព្ទគឺ ជាពាក្យពិត
ដែលសម្រាប់គិត បញ្ជាក់ណា
សេចក្តីសរសើរ តាមអក្ខរា
សប្បាយទុក្ខា ឆ្ងល់សង្ស័យ ៗ

៣– ពាក្យសួរ. អ្វីដែលហៅថា ឧទានសព្ទ? ពាក្យណាខ្លះដែលហៅថា ឧទានសព្ទ? អ្វីដែលហៅថា ឧទានសព្ទិកវិបទ:?

ចូរពណ៌នា -

## ៤ – វិធីហាត់សរសេរ.

ចូរអ្នកដាក់ពាក្យឧទានសព្ទ ឬ ឧទានសព្ទិកវិបទៈត្រង់កន្លែងដែលគូសបន្ទាត់.

– ជំរាបសួរលោក!

– ពួកសត្រូវ!

– កូននេះមិនខ្លាចប៉ាក់ទេ !

– គួរឲ្យតូចចិត្តពេក !

– កុំតែអញថា ប្រហែលជាខាតលិចលង់ !

– កំពុងអស់រលីង !

– អ៊ឺហ្ន៎ !

– ដូច្នោះទេឬ !

– អញ្ជើញមក !

– គេថាមិនឲ្យទៅបេះតែទៅ !

– គួរអណោចអធម្មទឹងសេចក្តីស្លាប់

– ខ្លួនកំព្រាតែម្នាក់ឯង –

– អឺបុះទេឬ !

– បែកបានទៅហើយ !

# ការផ្សាយរបស់

លេខ ៨៨ វិថី អែមេក្រង់ ភ្នំពេញ

គឺនៅផ្លូវខាងជើងវត្តឧណ្ណាលោម ត្រង់ទៅលិច ផ្លូវខាង

កើតវត្តសារាវ័ន្តត្រង់ទៅជើង រំលងផ្លូវមួយផ្លូវ ដល់កាច់ជ្រុងវិលមក

លិចបន្តិច គឺនៅខាងកើតរោងកុនព្រហ្មបាយ័ន្តផ្ទាល់ ។

---

## សេចក្តីជូនដំណឹង

បណ្ណាគារខ្ញុំបាទ មានទទួលចងក្រងសៀវភៅ មានដារព្រះពុទ្ធរូប ។ ចិត្រផ្សេងៗគឺ ព្រះឆាយាលក្ខណ៍នៃព្រះករុណា និងសម្តេចព្រះសង្ឃនាយកជាដើម ព្រមទាំងសៀវភៅធម៌ សៀវភៅរឿង គ្រឿងសរសេរ សង្ឃដីកា ឆាយា សំបុត្រកំណើត កាតកូនសិស្សនិង សៀវភៅខ្មែរ - បារាំង - អង់គ្លេស ផ្សេងៗ សម្រាប់កូនសិស្ស - គ្រូ ជាច្រើន ។

សូមនិមន្ត និងអញ្ជើញលោកអ្នកចូលជាវទិញ ដោយមេត្រីភាព ។

បើទិញដុំ យកទៅលក់ទៀត ខ្ញុំគិតរង្វាន់ជូនយ៉ាងគួរសំ ។

ព. ស ២៤៩៧ គ. ស. ១៩៥៥

( រោងពុម្ព ភក-ភ៉ ភ្នំពេញ )

ថ្លៃ ២០៛០០